# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ទុយ ឌុច ភេទ ប្រុស អាយុ ៤៥ ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ កងការពារនៅមន្ទីរក្រាំងតាចាន់
## ភូមិត្រាវឯម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ
## នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៥
## សម្ភាសន៍ដោយៈ ដួង សុភារិទ្ធ
## សរុបៈ ៣៣ទំព័រ

ឌុចៈ មានរឿងអី ដែលត្រូវភ្លេចទេ ហើយមានអី មានរណាមកសំឡុតខ្ញុំទេ ។

ភារិទ្ធៈ ហ្នឹងហើយខ្ញុំចង់អោយពូទុកចិត្ត ដើម្បីអោយនិយាយទៅ វា ព្រោះអី ខ្ញុំចង់ដឹងតែរឿងពិតកាលពីជំនាន់នោះទេណា ។

ឌុចៈ បាទ!

ភារិទ្ធៈ អញ្ចឹង ដូចខ្ញុំជំរាបពូ ពីគោលបំណង ពីកន្លែងដែលខ្ញុំធ្វើការអីហ្នឹងហើយអស់ហើយ ពូមានចម្ងល់អី សួរនាំដែរឬអត់ទេ ដូចថាចង់ឆ្ងល់ ចង់សួរនាំមកខ្ញុំវិញ គឺអាចសួរបាន ។

ឌុចៈ ខ្ញុំដូចជាគ្មានរឿងអីឆ្ងល់ ។

ភារិទ្ធៈ បាទ! អញ្ចឹងខ្ញុំចាប់ផ្ដើមសួរពូតែម្ដង កុំអោយចេះតែរំខានពូច្រើនពេក ។

ឌុចៈ បាទ!

ភារិទ្ធៈ ខ្ញុំចង់ស្គាល់ឈ្មោះពូសិន?

ឌុចៈ ខ្ញុំឈ្មោះឌុច ។

ភារិទ្ធៈ ឈ្មោះអីឌុចដែរ?

ឌុចៈ ទុយ ។

ភារិទ្ធៈ ទុយ ឌុច

ឌុចៈ បាទ!

ភារិទ្ធៈ ហើយសព្វថ្ងៃពូមានអាយុប៉ុន្មានដែរ?

ឌុចៈ ខ្ញុំអាយុ៤៥ ឆ្នាំ ។

ភារិទ្ធៈ ៤៥ឆ្នាំ?

ឌុចៈ បាទ!

ភារិទ្ធៈ ពូមានស្រុកកំណើតកើតជានៅឯណាដែរ?

ឌុចៈ ខ្ញុំកើតនៅភូមិអង្គតានូ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ។

ភារិទ្ធៈ អូ! ហើយចុះទីលំនៅសព្វថ្ងៃដែលពូរស់នៅហ្នឹង គេហៅ?

ឌុចៈ សព្វថ្ងៃនៅភូមិត្រាវឯម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

ភារិទ្ធៈ ភូមិអីគេ?

ឌុចៈ ភូមិត្រាវឯម ។

ភារិទ្ធៈ ត្រាវឯម?

ឌុចៈ បាទ! ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

ភារិទ្ធៈ ស្រុកត្រាំកក់ ខេត្តតាកែវ ។

ឌុចៈ ខេត្តតាកែវ ។

ភារិទ្ធៈ ហើយចុះពូរៀបការនៅឆ្នាំណាដែរ?

ឌុចៈ ខ្ញុំការនៅឆ្នាំ ១៩៧៩ ។

ភារិទ្ធៈ ១៩៧៩?

ឌុចៈ មកពីក្រោយរំដោះ ។

ភារិទ្ធៈ អូ! ការនៅឯណាដែរ?

ឌុចៈ ការនៅភូមិត្រាវឯមតែម្ដង ។

ភារិទ្ធៈ ប្រពន្ធពូឈ្មោះអីដែរ?

ឌុចៈ ឈ្មោះ វុន ។

ភារិទ្ធៈ ឈ្មោះអី វុន?

ឌុចៈ គល់ ។

ភារិទ្ធៈ គល់ វុន គាត់អាយុប៉ុន្មានហើយ?

ឌុចៈ អាយុប្រហាក់ប្រហែលគ្នា ។

ភារិទ្ធៈ  អូ! ស្រុកកំណើតគាត់នៅឯណា?

ឌុចៈ  នៅឯហ្នឹងតែម្ដង ។

ភារិទ្ធៈ  អូ! ហើយអើ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ឌុចៈ  ខ្ញុំមានកូន៥នាក់ ។

ភារិទ្ធៈ  ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ឌុចៈ  ប្រុស មួយ ស្រី ៤ ។

ភារិទ្ធៈ  កូននៅជុំគ្នាតើ?

ឌុចៈ  នៅជុំគ្នាទាំងអស់ ។

ភារិទ្ធៈ  កូនបងគេអាយុប៉ុន្មានហើយ?

ឌុចៈ  កូនបងគេ អាយុ ២៧ ២៨ឆ្នាំហើយ ។

ភារិទ្ធៈ  មានបានការកូនទេ?

ឌុចៈ  ការមួយហើយនេះ គ្រួសារគេអង្គុយអេ ។

ភារិទ្ធៈ  អោះ កូន ឃើញជៅដោះ ។

ឌុចៈ  បាទ ។

ភារិទ្ធៈ  ហើយចុះឪពុកពូឈ្មោះអីដែរ?

ឌុចៈ  ឪពុកខ្ញុំឈ្មោះងិល ។

ភារិទ្ធៈ  ងិល ឈ្មោះអីងិល?

ឌុចៈ  ទុយ ។

ភារិទ្ធៈ  ទុយ ងិល ។

ឌុចៈ  បាទ!

ភារិទ្ធៈ  ហើយគាត់រាល់ថ្ងៃនៅរស់?

ឌុចៈ  រស់ ។

ភារិទ្ធៈ  នៅឯណា?

ឌុចៈ  នៅភូមិតានូហ្នឹង នៅស្រុកកំណើត ខាងកើតហ្នឹង ។

ភារិទ្ធៈ  អូ! អញ្ចឹងស្រុកកំណើតគាត់នៅអង្គតានូហ្នឹង?

ឌុចៈ បាទ!

ភារិទ្ធៈ ហើយចុះម្ដាយ?

ឌុចៈ ម្ដាយនៅដែរ ឈ្មោះជឹម ។

ភារិទ្ធៈ ជឹម អីជឹម?

ឌុចៈ មាស ជឹម ។

ភារិទ្ធៈ មាស ជឹម នៅរស់ដូចគ្នា?

ឌុចៈ បាទ!

ភារិទ្ធៈ នៅអន្លង់វែងហ្នឹងដែរ?

ឌុចៈ បាទ!

ភារិទ្ធៈ ហើយពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ឌុចៈ បងប្អូនបង្កើតខ្ញុំវា ៧, ៨នាក់ ប៉ុន្តែស្លាប់អស់ពីរហើយ ។

ភារិទ្ធៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ឌុចៈ ប្រុស ដូច៤ ស្រីបី ។

ភារិទ្ធៈ អូ ៧នាក់អញ្ចឹង ?

ឌុចៈ អូ ប្រុស៤ ។

ភារិទ្ធៈ អូ ប្រុស៤ ស្រី៤ អញ្ចឹង?

ឌុចៈ បាទ!

ភារិទ្ធៈ ស្លាប់ប៉ុន្មាននាក់?

ឌុចៈ ស្លាប់ពីរនាក់ ។

ភារិទ្ធៈ ប្រុសអេស្រី?

ឌុចៈ ស្រីទាំងពីរ ។

ភារិទ្ធៈ កូនទីប៉ុន្មានអ្នកដែលស្លាប់ហ្នឹង?

ឌុចៈ អឺ កូនទី៦, ទី៧ហ្នឹងហើយ វាដូចជា ។

ភារិទ្ធៈ ហើយស្លាប់ដោយសារអីដែរ?

ឌុចៈ កាលជំនាន់ប៉ុលពតហ្នឹង គេជម្លៀសឪពុកម្តាយខ្ញុំគេមិនមែនអោយនៅហ្នឹងទេ គេអោយទៅនៅកោះអណ្តែតណោះ ។ ទៅដាច់បាយ ស្លាប់ទៅ ហើយយាយមួយទៀត យាយ យាយខ្ញុំ គាត់ស្លាប់ដាច់បាយដែរ ។

ភារិទ្ធៈ អញ្ចឹងបងប្អូនទាំងពីរនាក់ស្លាប់ដាច់បាយ?

ឌុចៈ បាទ! ដាច់បាយ យាយខ្ញុំក៏ស្លាប់ដាច់បាយដែរ គាត់អត់ ដល់តែរាគខ្លាំងមែនទែនទៅ ធ្វើអី អត់ដាប់ស្លាប់ ។

ភារិទ្ធៈ ស្លាប់ពេល ឆ្នាំណាដែរ?

ឌុចៈ ឆ្នាំ៧៧, ៧៨ ពីរឆ្នាំហើយ ប៉ុន្តែ កំឡុងពេលហ្នឹងមិនដឹងប៉ុន្មាន វាភ្លេចហើយ យូរហើយ ។

ភារិទ្ធៈ ហើយចុះពូអាការដែលរដ្ឋប្រហារឆ្នាំ៧០ ពូនៅឯណាដែរ?

ឌុចៈ ខ្ញុំកាលពីរដ្ឋប្រហារឆ្នាំ ៧០ ខ្ញុំនៅរៀន នៅវិទ្យាល័យ ១ ឧសភាអោះ ពីដើមគេហៅវិទ្យាល័យកូនចៅសម្តេចឪ ទៅណា ។

ជាតិៈ វិទ្យាល័យកូនចៅសម្តេចឪ ?

ឌុចៈ បាទ វិទ្យាល័យកូនចៅសម្តេចឪ ដល់តែហើយ គេគាស់អាហ្នឹងចេញទៅ គេដាក់ ជំនាន់លន់ នល់ គេដាក់វិទ្យាល័យដើមសំបុក ក្រោយរំដោះឆ្នាំ៧៩មក គេដាក់វិទ្យាល័យ ១ ឧសភា ។

ភារិទ្ធៈ ពូ រៀនបានថ្នាក់ទីប៉ុន្មានដែរ?

ឌុចៈ ថ្នាក់ទី៦ ខ្ញុំទើបតែប្រលង កុងកក់ ព្រោះខ្ញុំអាយុនៅតិច កាលហ្នឹងប្រលងអត់កើតទេ គេអោយទៅដូរបញ្ជីរជាតិ ។ ដូរបញ្ជីរជាតិ ដាក់អាយុ១៨ឆ្នាំ បានប្រលងកុងកក់ ។

ភារិទ្ធៈ ហើយចុះកាលរដ្ឋប្រហារកាលពីឆ្នាំ៧០ហ្នឹង នៅក្នុងភូមិពូ ដែលពូរស់នៅហ្នឹង មានរឿងរ៉ាវអីខ្លះដែលកើតឡើង?

ឌុចៈ អឺ រឿងរ៉ាវច្រើន អូនប៉ុន្តែដូចជាអត់ចាំទេ ភ្លេចហើយ ។

ភារិទ្ធៈ បាទ!

ឌុចៈ ភ្លេចហើយជំនាន់ហ្នឹង ។

ភារិទ្ធៈ ហើយចុះខ្មែរក្រហម ចូលកាន់កាប់ភូមិពូ តាំងពីឆ្នាំណាមក?

ឌុចៈ ចូលជាប់តែម្តង ដូចជាឆ្នាំ៧៤ហើយ ចូលជាប់៧៤ហើយ ៧៤, ៧៥ ព្រោះកាលហ្នឹង វាឆ្នាំ១៩៧៣គេវាយ មិនទាហានយើងនៅអង្គតាសោម ។ គេវាយនៅអង្គតាសោមបែក ៧៣ ហើយហ្នឹង ៧៣, ៧៤ ទាហានចូលមកមួយសារទៀត ។ ដល់តែ៧៥ បានចេញ ។

ភារិទ្ធៈ អូ ពីព្រោះពូនៅលាយបូរអានេះ?

ឌុចៈ បាទ! នៅលាយបូរអាណោះ ហើយបានជម្លៀសមកនេះ ។

ភារិទ្ធៈ ខ្ញុំចេះតែចង្អុលទៅ ។

ឌុចៈ មកនេះ គេថាតំបន់រំដោះគេទៅណា ហើយតំបន់យើងនោះ គេហៅតំបន់ខ្មាំងកាន់កាប់ តំបន់ប្រទាញប្រទង់ហ្នឹងអាំ ហៅថា តំបន់ស នោះ ។

ភារិទ្ធៈ ហើយចុះដល់តែពេលខ្មែរក្រហម ដូចថា វាយបែកអង្គតាសោម ហើយនេះហើយ ដូចថា គេអោយពូធ្វើអីដែរ?

ឌុចៈ ខ្ញុំកាលហ្នឹង នៅកងកុមារ ។ ចេញពីកងកុមារ មកនៅកងឃើញទ្រើសបន្តិចគេអោយទៅ កងយុវជន ធ្វើទំនប់ ធ្វើប្រឡាយហ្នឹង ដល់ឆ្នាំហ្នឹង អេ ចុង៧៦ ដើម៧៧ អញ្ចេះទេ ខ្ញុំភ្លេចហើយ ។ ខ្ញុំ ចូលគេកេណ្ឌទ័ព ចូលធ្វើកងទ័ព ។ មុនដំបូងខ្ញុំនៅទ័ពស្រុកទេ ក្រោយមកគេអោយឡើងតំបន់ ។

ភារិទ្ធៈ អូ!

ឌុចៈ ប៉ុន្តែកាលហ្នឹងមិនដឹងស្អីអាណាទេ អត់ចាំទេ ដឹងស្រុក កងប៉ុន្មានទេ អត់ដឹងទេ ចេះតែទៅតាមគេហើយ ។ អោយទៅ ចេះតែទៅអញ្ចឹងហើយ ចេះតែទៅ ទៅអញ្ចឹងទៅ ដល់តែហើយក្រោយមក បានគេអោយនៅកងពិសេស ពិសេស គេដាក់ធុន១៣ អាហ្នឹងចាំ អាហ្នឹងគេលែង អោយយើងទៅមុខហើយណា គេអោយយើងនៅចាំក្រោយអញ្ចឹង ដូចថាពួកគេវាយ ទៅមុខអញ្ចឹងទៅ ដូចថាយើងក្មេងៗហ្នឹង ចាំរែកបាយ រែកទឹកអីហ្នឹងអាំ កងហ្នឹងស្រណុក បាទស្រណុក ចូលកងពិសេសហ្នឹងបានខ្ញុំដូចចូលខ្ទីដែរ ដូចជា៧៨ហើយ អត់មានបានវាយ បានអីគេឯណាជិតបែកហើយ ដល់តែហើយ ៧៩ បែកតែម្តង ។

ភារិទ្ធៈ អូ!

ឌុចៈ នៅ គ្រាន់តែចាំ នៅកងពល, កងពលលេខ៤ វរសេនាធំ១៣ កងពលតូច២១០ ។

ភារិទ្ធៈ អូ!

ឌុចៈ បាទ! កងពលតូច២១០ វរសេនាធំ១៣ អនុសេនាធំ២៣, ២៤ ភ្លេចទៀតហើយ ។

ភារិទ្ធៈ ហើយចុះពូការដែលពូថានៅកង នរណាគេប្រធានកងពូ?

ឌុចៈ ប្រធានកង មេបញ្ជាការកង វរសេនាធំរបស់ខ្ញុំហ្នឹង បងថា ហើយបងមាន ។

ភារិទ្ធៈ អូ នៅរស់ដែរ សព្វថ្ងៃហ្នឹង?

ឌុចៈ អត់ដឹង មិនដឹងនៅរស់អេស្លាប់ មិនដឹងពីណាគេទេ ។

ភារិទ្ធៈ ហើយចុះនរណាគេនាំពូ ចូលធ្វើទ័ពធ្វើអី?

ឌុចៈ អាហ្នឹង ភូមិឃុំគេ សុទ្ធតែ យើងតែដល់អាយុ ជំនាន់ហ្នឹងអោយតែអាយុ យើងធ្វើយុវជន គឺគេជំរុញហើយ មិនខុសពីជំនាន់៧៩ ដែលថាដើរចាប់ទាហានទេ ប៉ុន្តែគេច្រើនអត់ចាប់ គេជំរុញអោយយើងទៅតែម្តង យើងមិនទៅ យើងអត់បាយស៊ី ដូចម៉ែឪអញ្ចឹង ត្រូវបញ្ជូនកូនទៅកងទៅ ។

ភារិទ្ធៈ បាទ ម៉ែឪដឹងដែរពេលចូលទៅ?

ឌុចៈ អឺមិនដឹង ម៉ែឪយើងធ្វើម៉េចចេះតែទ្រាំអញ្ចឹងទៅ ជំរុញទៅ ។

ភារិទ្ធៈ ហើយចុះប្រធានឃុំឈ្មោះអី ជំនាន់ហ្នឹង?

ឌុចៈ អឺ ខ្ញុំកាលហ្នឹង ដូចអត់ចាំទេ ប្រធានឃុំ ប្រធានភូមិ មិនដឹងជាអាណា ប្រធានភូមិ អាណាប្រធានឃុំទេ អត់ចាំអារម្មណ៍ទេ ដឹងតែកាលហ្នឹង មេឈ្លបគេ តាប៉ុន ។

ភារិទ្ធៈ តាប៉ុន?

ឌុចៈ ដឹងតែប៉ុណ្ណឹងអេ ហើយប្រធានភូមិ ប្រធានឃុំវាច្រើន មិនដឹងអាណា ជាអាណើទេ ។

ភារិទ្ធៈ ហើយអញ្ចឹងដំបូង ពូធ្វើឈ្លបអញ្ចឹងអេ?

ឌុចៈ មុនដំបូងនៅឈ្លបឃុំ ។

ភារិទ្ធៈ នៅជាមួយតាប៉ុនហ្នឹងអេ?

ឌុចៈ ហ្នឹងហើយ នៅជាមួយតាប៉ុន ហ្នឹង ខ្ញុំនៅហ្នឹង អត់បានពេលវែងទេ ។

ភារិទ្ធៈ បានរយៈពេលប៉ុន្មាន?

ឌុចៈ បានរយៈប្រហែលជាពីរខែទេ ។

ភារិទ្ធៈ អូ!

ឌុចៈ គេបញ្ជូនទៅទៀតហើយហ្នឹង គេថាស្នាក់ទៅស្រុក ។

ភារិទ្ធៈ ស្រុក ។

ឌុចៈ មុនដំបូងចូលឃុំ ឃុំហើយទៅស្រុក ។

ភារិទ្ធៈ នៅស្រុកហ្នឹងក្រោមបញ្ជារពីណាគេ?

ឌុចៈ អត់ ។

ភារិទ្ធៈ ក្រោមការដឹកនាំពីណាគេ?

ឌុចៈ អត់ដឹងរលីង ។

ភារិទ្ធៈ ហើយចុះនៅស្រុកហ្នឹង នរណាគេចៅហ្វាយស្រុក?

ឌុចៈ អេ អត់ដឹងទេ ចៅហ្វាយស្រុកអត់ដឹងទេ ។

ភារិទ្ធៈ ហើយចុះពូទៅស្រុកហ្នឹង ទៅធ្វើការជាមួយ?

ឌុចៈ និយាយអញ្ចេះអូនអា៎ មួយក្រុម ឧទាហរណ៍ថា ឈ្លបមានគ្នា ១០នាក់ ។

ភារិទ្ធៈ បាទ!

ឌុចៈ ២០នាក់អញ្ចឹងអាណា ។

ភារិទ្ធៈ បាទ ។

ឌុចៈ ឃុំពពេល ឃុំលាយបូរ ១០-២០នាក់ ឃុំញ៉ែញ៉ង ៨-១០-២០នាក់ ឃុំឧត្តម សុរិយា ៨-១០-២០នាក់ អញ្ចឹងពេលដូចថា គេរើសបានពីឈ្លបមុនដំបូង យកមក ដាក់ត្រឹមឈ្លប គេថាឯងមិនបាច់ទៅណាទេ គេអត់អោយទៅណាឆ្ងាយទេ ។

ភារិទ្ធៈ បាទ ។

ឌុចៈ ទៅនៅត្រឹមហ្នឹងទៅ ត្រឹមឈ្លបហ្នឹង ដើរមើលគេត្រេតត្រតៗ ទៅ ។

ភារិទ្ធៈ បាទ ។

ឌុចៈ បាន! ៨-១០ថ្ងៃ គេបញ្ជូនទៅណា បញ្ជូនទៅកងស្រុក នៅកងស្រុកហ្នឹង មិនដឹងជា អាណា កងអាណា មាអាណាអីទេ គេអោយដេក ដេកទៅ ស៊ីបាយស៊ីទៅ ។

ភារិទ្ធៈ គេអោយធ្វើអីឈ្លប?

ឌុចៈ ឈ្លប កាលពីជំនាន់ហ្នឹងទៅនៅសមរភូមិដែរហ្នឹង ប៉ុន្តែដូចថា ទ័ពគេវាយខាងមុខទៅ យើង នៅខាងក្រោយអញ្ចឹងទៅណា អានេះដូចថាមុនដំបូងគេថា ដូចបង្រៀនយើងអញ្ចឹង ។

ភារិទ្ធៈ អូ ។

ឌុចៈ  គេដូចថា គេបង្វឹកហាត់យើង ដូចជាក់ស្តែងហើយណា ទៅដល់សមរភូមិ ដឹងកន្លែងបាញ់ អីអញ្ចឹងទៅ ។

ភារិទ្ធៈ  ហើយចុះនៅស្រុកបានរយៈពេលប៉ុន្មាន?

ឌុចៈ  ខ្ញុំនៅស្រុកហ្នឹង បានរយៈពេលប្រហែលជាពីរ បីខែទៀត ។

ភារិទ្ធៈ  អូ ។

ឌុចៈ  ថ្នាក់ៗជាន់អញ្ចឹង គេចេះតែបញ្ជូនៗអញ្ចឹងទៅណា ។

ភារិទ្ធៈ  ហើយគេបញ្ជូនទៅណាទៀត?

ឌុចៈ  ហើយគេបញ្ជូនទៅតំបន់ ។

ភារិទ្ធៈ  តំបន់?

ឌុចៈ  ហ្នឹងហើយ ។

ភារិទ្ធៈ  តំបន់នៅឯណាវិញ?

ឌុចៈ  អូនអើយ អត់ដឹងឯណាទេ ច្រើនត្រឡប់ត្រឡិនៗ រកចាំ អត់ឃើញទេ ។

ភារិទ្ធៈ  អូ!

ឌុចៈ  វាកាលពីជំនាន់ហ្នឹង អូនឯងដើរមួយថ្ងៃទល់យប់អីវ៉ាន់ ដល់តែយប់ ដើរមួយយប់ទល់ភ្លឺអញ្ចឹងទៅ ដល់តែកន្លែងណាមានព្រៃមានអីទំនង ចងអង្រឹងដេកអញ្ចឹងទៅណា ថ្ងៃដេកអញ្ចឹងទៅ ដូចថាដឹងជារកទិស ហើយដឹងវេរឯណា មិនដឹងជាកលឯណា ឯណា អត់ដឹងទេ មួយគន្លាក់ហ្នឹងអត់ដឹងទាំងអស់ ។

ភារិទ្ធៈ  នរណាគេ ប្រធានតំបន់?

ឌុចៈ  អត់ដឹង ។

ភារិទ្ធៈ  អត់ដឹង?

ឌុចៈ  អត់ស្គាល់ទេ ។

ភារិទ្ធៈ  ហើយចុះចេញពីនៅខាងតំបន់ហ្នឹង រយៈពេលប៉ុន្មាន?

ឌុចៈ  នៅតំបន់ហ្នឹងប្រហែលជាពីរ បីខែទៀត ហើយឡើងទៅភាគ ។

ភារិទ្ធៈ  ភាគ?

ឌុចៈ  កងពលហ្នឹងតែម្តង ។

ភារិទ្ធៈ អូ នរណាគេប្រធានកងពល?

ឌុចៈ ប្រធានកងពលលេខ៤ហ្នឹង បែបតាម៉ុកហ្នឹងហើយ តាមមើល ប៉ុន្តែខ្ញុំមិនច្បាស់ដែរណា អាហ្នឹងគ្រាន់តែជាបញ្ហាសន្និដ្ឋានទេ ។

ភារិទ្ធៈ បាទ!

ឌុចៈ តាម៉ុកហ្នឹងទេ ប៉ុន្តែខ្ញុំដឹង កងពល ២១០ អត់ដឹងមេបញ្ជាការហ្នឹង ។

ភារិទ្ធៈ ឈ្មោះអីទៀត?

ឌុចៈ ដឹងវរសេនាធំ១៣ ខ្ញុំនៅជាមួយហ្នឹង បានស្គាល់អ្នកនៅជាមួយហ្នឹងតែម្តង ។

ភារិទ្ធៈ ឈ្មោះអី?

ឌុចៈ ថាហើយមាន ។

ភារិទ្ធៈ អូ!

ឌុចៈ ដឹងតែពីរនាក់ ថាបញ្ជាការ អូ! បងមាន បញ្ជាការថាហ្នឹង ស្នងការ ។

ភារិទ្ធៈ ហើយចុះចេញពីហ្នឹងមកទៀត?

ឌុចៈ ចេញពីហ្នឹងមក អត់ចេញទេ នៅហ្នឹងរហូតដល់តែបែកហើយ ។

ភារិទ្ធៈ ហើយចុះពូថាទៅនៅ?

ឌុចៈ ក្រោយទៀត ។

ភារិទ្ធៈ បាទ!

ឌុចៈ ឆ្នាំ១៩៧៥ មិនយើងបែកហើយណា ។

ភារិទ្ធៈ បាទ!

ឌុចៈ ដល់តែខែចូល ៧៥-៧៦ ឆ្នាំ៧៦ ខ្ញុំទៅនៅស្រុកក្រោម ទៅធ្វើស្រែប្រាំង ទៅនៅទំព ហើយបែកហើយហ្នឹង មុនដំបូងមិនបានធ្វើផ្ទះ ធ្វើអីអោយប្រជាជន ផ្ទះគំរូគេហ្នឹង ។

ភារិទ្ធៈ បាទ ។

ឌុចៈ ដល់តែធ្វើផ្ទះ ធ្វើថ្នល់ អីហ្នឹង ។

ភារិទ្ធៈ ផ្ទះគំរូហ្នឹង គេធ្វើយ៉ាងម៉េច?

ឌុចៈ ផ្ទះគំរូហ្នឹង គេធ្វើដូចជាភូមិហ្នឹងមួយហ្នឹង គេលើកផ្ទះគំរូមួយខ្នងគំរូ ទទឹង៤ម៉ែត្រ បណ្តោយ៦ហ្នឹង អោយប្រជាជនមូលដ្ឋានគេនៅ ខ្ញុំធ្វើនៅធ្នង់រលើងនេះ លាយបូរ

ហើយដឹងត្រង់ណាទៀតទេ ច្រើនខ្ញុំភ្លេចហើយ វាដូចរកចាំមិនបាន ដូចវាដើរច្រើនពេក វាដើរច្រើនពេក វាចាំមិនបាន ហើយខ្ញុំធ្វើជាងត្រឹមហ្នឹងមក ។

ភារិទ្ធៈ ហើយចុះពូថា ពូទៅធ្វើនៅក្រាំងតាចាន់?

ឌុចៈ អាហ្នឹងដល់តែឆ្នាំ ១៩៧៨ ចុង៧៧ ដើម៧៨ហើយ ។

ភារិទ្ធៈ បាទ ។

ឌុចៈ ៧៩ហើយ គេរើសពីកងទ័ពមក អោយទៅកងការពារ ទៅកងការពារគេ គេរើសពីទ័ព ហើយដល់ស្ទូង ទ័ពគេអោយស្ទូងដែរ កងការពារ កងការពារនៅក្រាំងតាចាន់ហ្នឹង ។

ភារិទ្ធៈ នៅរយៈបាន?

ឌុចៈ នៅប្រហែលជា៦-៧ខែ មិនដឹងជាប៉ុន្មានទេ ប្រហែលជាប៉ុណ្ណឹង យើងមិនចាំច្បាស់ ។

ភារិទ្ធៈ បាទ! ហើយនៅទាល់តែបែកអេ?

ឌុចៈ បែក អត់ទេ អត់ទាន់បែកទេ មុនបែក មុនបែកចេញ ចេញកាលពី កាលយើងស្វាយរៀងមិនមុន អើបភើបកាលហ្នឹងស្វាយរៀងមិនមុនគេ

ភារិទ្ធៈ អើបភើបយ៉ាងម៉េច?

ឌុចៈ អើបភើប មិនថាយួនបុកចូល ។

ភារិទ្ធៈ បាទ!

ឌុចៈ ហ្នឹងហើយ អាហ្នឹង មិនដកចេញ ។

ភារិទ្ធៈ អូ!

ឌុចៈ ដកចេញមិនមកកងនៅហ្នឹងវិញ ។

ភារិទ្ធៈ កងនៅឯណា?

ឌុចៈ កងខ្ញុំ កាលហ្នឹង នៅឯផ្លូវជាតិលេខ៨ ។

ភារិទ្ធៈ អូ!

ឌុចៈ ចេញមកកងខ្ញុំវិញមក ។

ភារិទ្ធៈ ហើយចុះអ្នកធ្វើការនៅក្រាំងតាចាន់ជាមួយពូ មានស្គាល់ឈ្មោះអីខ្លះដែរ?

ឌុចៈ ឈ្មោះ អ្នក ឈ្មោះ អេ ភ្លេចអស់ហើយ វានៅកងការពារជាមួយគ្នាហ្នឹង វានៅកងការពារ ជាមួយគ្នាហ្នឹង ។

ភារិទ្ធៈ បាទ!

ឌុចៈ វាមានគ្នា ៥-៦នាក់ ។

ភារិទ្ធៈ បាទ!

ឌុចៈ អ្នក ឈ្មោះស្អីៗ អាណាទេភ្លេចហើយ នឹកមិនឃើញទេ ។

ភារិទ្ធៈ មាននៅរស់ឬអត់?

ឌុចៈ ទេ វាបែកគ្នា មិនមែនស្រុកកំណើតជាមួយគ្នាផង ខ្លះនៅស្អី ខ្លះនៅបាត់ដំបង ខ្លះនៅឯណានោះ មិនដឹង ។

ភារិទ្ធៈ ហើយចុះដូចថា អ្នកហ្នឹងមានលក្ខណៈសម្បត្តិអីខ្លះ បានគេអោយមកការពារនៅ?

ឌុចៈ វាមិនមែនទេ កន្លែងហ្នឹង ដូចថាកន្លែងកងទ័ពអញ្ចឹង គេរើសអោយមក ដំណើរខ្ញុំយល់ដំណើរអញ្ចេះទេ វាមិនដឹងជាយើងយកជាការពិតបាន ឬមិនបានទេណា ប៉ុន្តែខ្ញុំតាមស្មានមើលទេណា ។

ភារិទ្ធៈ បាទ!

ឌុចៈ អានេះមិនខុសពីយកត្រី មកដាក់នៅជ្រលមាត់ដុចទេ ព្រោះខ្ញុំអីពាក់ព័ន្ធច្រើនរឿងរ៉ាវខ្ញុំច្រើន ។

ភារិទ្ធៈ ពាក់ព័ន្ធអីខ្លះទៅ?

ឌុចៈ ដូចជាបងប្អូនខ្ញុំសុទ្ធតែធ្វើទាហាន ទាហានលុន នល់ ហើយជីដូនមួយនោះគេសម្លាប់ មាខ្ញុំគិតទៅ បងប្អូនខាងម៉ែបីនាក់ ធ្វើទាហានទាំងអស់ នៅតែម៉ែខ្ញុំទេ ហើយឪខ្ញុំអត់មានបងប្អូនទេ ទោសម្នាក់ឯង អញ្ចឹងវាពាក់ព័ន្ធអស់ហើយ ហើយខ្ញុំវាអត់ដែលបានចូល វាពេញសិទ្ធគេអីទេ អត់ទេ នៅតែត្រៀម ប្រជាជនត្រៀមហ្នឹង ។

ភារិទ្ធៈ អូ!

ឌុចៈ អត់ដែលបាននេះទេ ម៉ែឪខ្ញុំ សុទ្ធតែត្រៀមហើយ មិនដែលបានពេញសិទ្ធគេទេ ។

ភារិទ្ធៈ ត្រៀមពេញសិទ្ធ ធ្វើរហ្នឹង យ៉ាងម៉េច?

ឌុចៈ អត់យល់ លឺតែពាក្យ គេថាអញ្ចឹងមក ពេញសិទ្ធត្រៀមធ្វើរអញ្ចឹង មិនដឹងជាគេចង់និយាយ ន័យហ្នឹងយ៉ាងម៉េចវិញ ខ្ញុំអត់យល់ ។

ភារិទ្ធៈ ហើយចុះនៅក្នុងចំណោមដែលថា៦នាក់ដែលពូនៅហ្នឹងនរណាគេប្រធានគេ?

ឌុចៈ    ប្រធានគេពួក ។

ភារិទ្ធៈ  ពួក

ឌុចៈ    ចាស់ជាងគេ ។

ភារិទ្ធៈ  អូ!

ឌុចៈ    ពួកហ្នឹងគាត់មានអាយុប្រហែលជា  កាលពីជំនាន់ហ្នឹងប្រហែល២០ជាងហើយ  ព្រោះគាត់មានប្រពន្ធមានកូនហើយកាលពីជំនាន់ហ្នឹង ២០ ចូល៣០ហើយ គាត់ចាស់ជាងគេ ។

ភារិទ្ធៈ  ហើយចុះពូ  កាលពូធ្វើនៅយាម  ពូនៅក្នុងរយៈពេលដែលពូនៅហ្នឹង  តើពូមានដែលឃើញគេយកអ្នកទោសអ្នកអីមកដែរ?

ឌុចៈ    អីមិនឃើញអ្នកទោសគេយកមក ។

ភារិទ្ធៈ  មកពីណាវិញ?

ឌុចៈ    មកទាំងខ្មែរៗតែម្តង ។

ភារិទ្ធៈ  មកពីណាវិញ?

ឌុចៈ    អឺ  ពេញទឹកពេញដីតែម្តងនរណាក៏បញ្ជូនទៅដែរ ។

ភារិទ្ធៈ  មានអ្នកមកពីភ្នំពេញដែរឬអត់ទេ?

ឌុចៈ    អាហ្នឹងក្រោយហើយ  អាហ្នឹងពីភ្នំពេញមកដូចថា  យើងរំដោះ៧៩អូន ។

ភារិទ្ធៈ  បាទ!

ឌុចៈ    ហើយដូចថា  វាចូលមកនៅប្រហែលជាមួយឆ្នាំ  ពីរឆ្នាំហើយ ។

ភារិទ្ធៈ  អូ!

ឌុចៈ    លែងស្គាល់ហើយ  លែងស្គាល់អ្នកភ្នំពេញ  អ្នកភ្នំពេញហើយ ។

ភារិទ្ធៈ  អ្នកដែលគេបញ្ជូនមកមានដឹងថា  ខុសអីទេ?

ឌុចៈ    អឺ  បើសិនជា  យើងនិយាយអោយរួមខ្លីមួយម៉ាត់ទៅថា  កំហុសកាលពីជំនាន់ហ្នឹង  ដែលធ្វើឡើងកើតឡើង   កំហុសតែរឿងអត់ស៊ីហ្នឹងតែម្តង      អោយតែឯងត្អូញហេវបន្តិចគឺងាប់ហើយ ។

ភារិទ្ធៈ  អឺ!

ឌុចៈ ត្អូញហេវគឺងាប់ហើយ សួរថាឯងស៊ីឆ្ងាញ់ដែររឺអត់ បើយើងមិនថាឆ្ងាញ់ ទោះមិនថាឆ្ងាញ់ ក៏ត្រូវថាឆ្ងាញ់ដែរ បើមិនឆ្ងាញ់ក៏ត្រូវចូលគុក ចូលគឺងាប់តែម្តង ហើយគ្មានកន្លែងត្រឡប់ទេ ចូលរាប់រយនាក់ មិនដែលឃើញ បញ្ជូនចេញមកវិញទេ ។

ភារិទ្ធៈ បាទ!

ឌុចៈ មិនដែលទេ ខ្ញុំមិនដែលឃើញចេញទេ និយាយរួមខ្ញុំនៅជិតមួយឆ្នាំមិនដែលឃើញនេះរួចពីគុក អានេះរួចពីអីទេ អត់ ។

ភារិទ្ធៈ ពូមានដែលឃើញ មានដែលធ្លាប់ឃើញគេសម្លាប់មនុស្សទេនៅហ្នឹង?

ឌុចៈ ទេ អារឿងបញ្ហាសម្លាប់នេះវា វាស៊ីជម្រៅណាស់ ហើយពិបាកយល់ទៀត វាមានច្រើនសណ្ឋានណាស់ ហើយយើងមិនអាចចូលជិតបាន បើយើងថាពីក្រៅទៅ ក្រែងល់វាថាទៅវាខុស ប៉ុន្តែស្ងាត់ឈឹងគ្មានលឺសូរស្អីផង លឺសូរថាបាញ់មួយទីងមួយទូងហ្នឹង ថាបាញ់សម្លាប់ បាញ់អីទៅណាស្ងាត់ហើយ យើងមើលទិដ្ឋភាពខាងក្រៅទៅ កាលហ្នឹង គុកហ្នឹងវាមិនមែនធំទេ វាតូចដែរទេ ហើយបើមនុស្ស នៅក្នុងមួយថ្ងៃយ៉ាងអន់បំផុត ក៏មានត្រឹម៣ទៅ៤នាក់ដែរ ហើយចុះមួយខែ ជួនកាលថ្ងៃណាច្រើនមាន១០នាក់ ២០នាក់ទាំងខ្សែអញ្ចឹងតែម្តង ហើយយកដាក់អាណាអស់ សុទ្ធតែមានអ្នកងាប់បន្តទៅតែម្តងកាលហ្នឹង ។

ភារិទ្ធៈ កន្លែងគេសម្លាប់មនុស្សហ្នឹងនៅឯណា?

ឌុចៈ កន្លែងក្រាំងតាចាន់ហ្នឹង ។

ភារិទ្ធៈ អូ នៅក្នុងហ្នឹង?

ឌុចៈ នៅក្នុងគុកហ្នឹង ចូលគឺបាត់នៅហ្នឹងតែម្តង មិនដឹងសម្លាប់ហ្នឹង ប៉ុន្តែយកចេញ ក៏ខ្ញុំឃើញពួកខ្ញុំឃើញដែរ អត់មានយកចេញទេ ។

ភារិទ្ធៈ ពូមានដែលចូលចេញ យកទំនាក់ទំនងអីទេ?

ឌុចៈ អត់ទេ អត់ដែលចូលទំនាក់ទំនងអីទេ យើងមិនហ៊ាននិយាយអីទេ ។

ភារិទ្ធៈ ហើយចុះដឹងថាគុកហ្នឹងមានប៉ុន្មានអាគារ?

ឌុចៈ យើងមើលទៅ ចង់និយាយពីអញ្ចេះ ឧទាហរណ៍ថាអានេះរបងមួយអាណា របងគេអញ្ចឹងអាណា របងគេព័ទ្ធជុំវិញហ្នឹង ខាងក្នុងនៃ យើងនាំពីនេះទៅអេ ។

ភារិទ្ធៈ បាទ ។

ឌុចៈ ចូលត្រឹមរបងហ្នឹងអេ ។

ភារិទ្ធៈ បាទ ។

ឌុចៈ របងជិតដែរ របងប្រហែលជាគុកនេះ ត្រឹមដើមដូងនេះ ត្រឹមគល់ដូងធំនេះ បានត្រឹមនេះ អាគារហ្នឹងវាពីរទៅក្ដោះ ។

ភារិទ្ធៈ អូ !

ឌុចៈ អាហ្នឹង ហៅពីខាងលិច ហើយអាពីខាងកើតនេះ ប្រហែលជាមួយ អេពីរទៀត មិនដឹង ។

ភារិទ្ធៈ អូ អញ្ចឹងអាច បី បួនអេ?

ឌុចៈ បាទ! អាច៣-៤ ប៉ុន្តែយើង ត្បិតតែកន្លែងប្រវែងហ្នឹង ប្រវែងហ្នឹង យើងមិនដែលហ៊ាន ចូលទេ ។

ភារិទ្ធៈ ហើយចុះគុកគេ ដែលគេដាក់ហ្នឹង គុកនៅ សំរាប់អ្នកទោសធ្ងន់ គុក?

ឌុចៈ អត់ដឹង ប៉ុន្តែវាសន្មតថាអញ្ចេះ សន្និដ្ឋានថាទោសគ្មានធ្ងន់គ្មានស្រាលទេ ជំនាន់ហ្នឹងអត់ ទោសត្រូវតែងាប់អញ្ចឹងតែម្តង មានទោសណា អើឯងត្រូវទោសធ្ងន់ទេ អានេះត្រូវទោស ស្រាលទេ អោយតែយកទៅ គឺងាប់តែម្តង អត់មានអេ ឯងដល់កំណត់រួចហើយ ឯងទោសស្រាល អានេះទោសធ្ងន់អីអត់ អត់ អត់ គ្មានស្រាល គ្មានធ្ងន់ទេ ជំនាន់នោះ អោយតែមានទោស គឺត្រូវតែងាប់ ហើយទោសក៏គ្មានទោសអីដែរ ទោសសំខាន់បំផុត គឺទោសអត់ស៊ីហ្នឹងតែម្តង គ្មានរឿងទោសរឿងនយោបាយនេះ នយោបាយនោះអីអត់ទេ ផ្លូវអ្នកឯងគួញទៅ អើឈ្លបគេ អេប្រធាន សហករណ៍គេហ្នឹង សួរថា អូនឯងឆ្ងាញ់ទេ បបរហ្នឹងឆ្ងាញ់ទេ ហ៊ានថាអត់ឆ្ងាញ់មើលល្ងាចបាត់ខ្លួនហើយខ្ញុំ ព្រោះខ្ញុំកាលពីជំនាន់ហ្នឹង នៅក្នុងឃុំហ្នឹងមានឈ្លបមួយនាក់ ខស្សាប់នាំឈ្លបហ្នឹង គេនាំ គេនាំមនុស្សមកដល់កន្លែង ខ្ញុំ ។

ភារិទ្ធៈ ឈ្មោះអីឈ្លប?

ឌុចៈ ភ្លេចឈ្មោះវាហើយ ឈ្លបហ្នឹងវាខស្សាប់មកអង្គុយនិយាយលេងថា ល្ងាចមិញអត់ បានដេកមួយយប់ វាថាអញ្ចឹង ។

ភារិទ្ធៈ បាទ!

ឌុចៈ ទៅអន្ទុយស្លាប់ពួកយុវជន គ្នាអត់ស៊ី ស៊ីបាយ ហើយវែកដី ហើយបន្ទុកប្រឡាយធំ យើងឃើញអាប្រឡាយព្រែកនៅខាងត្បូងហ្នឹង ជំរៅ៨ម៉ែត្រ ទទឹងមាត់លើ១០ម៉ែត្រជាង វែកកំលាំងមនុស្ស ហើយនៅក្នុងមួយនាក់ មួយថ្ងៃ៣០ម៉ែត្រគីប ហើយវាវែកដាក់បង្គីពីរ ដល់តែយប់ឡើងវាហៅ វាហត់វា ហើយដល់ ហើយវា អោយទៅស្លាប់ អោយឈ្លប ស្លាប់ ខ្លះដេកយំ ខ្លះដូចថាមិនដែលនឹកឃើញអតីតកាលវាមិនដឹង ស្អែកឡើងបាត់ ស្អែកឡើងយកគ្នាទៅបាត់ ជជែកគ្នាតែរឿងស៊ី អញ្ចឹងបានខ្ញុំថា រឿងនេះមិនមែនរឿង នយោបាយរឿងអីទេ រឿងតែ អត់ស៊ីតែប៉ុណ្ណឹង រឿងក្រពះ ងាប់ដោយសារក្រពះ ។

ភារិទ្ធៈ ម៉េចបានគេសម្លាប់មនុស្សអញ្ចឹង កាលហ្នឹងធ្វើបានអីបានដែរ?

ឌុចៈ អត់ទេ អូន អូនឯងមិនខុសនៅអង្គភាពមួយទេ ខ្ញុំនិយាយមួយម៉ាត់ សម័យឥលូវយើង មានសិទ្ធិប៉ុនគ្នា សម័យនោះអត់ទេ គេមេ គេសិទ្ធិធំជាងយើង អញ្ចឹងអូនឯងនៅក្នុងមួយ កងនេះ ត្រូវមើលតែមេមួយ ស្តាប់តែមេមួយទេ មេមួយអោយទៅលិច ទៅលិចហើយ ហើយអញ្ចឹងមានអាណាមកថាខុស បើមេថាអោយទៅហើយ ហើយយើងអាណា ហ៊ាន តគេ យើងឯណាហ៊ាននិយាយគេ អត់និយាយទេ បើថាហ៊ាននិយាយមួយម៉ាត់មើល បាត់ខ្លួនឥលូវ ដូចខ្ញុំថាអញ្ចឹង គ្មានទោសស្រាល ទោសធ្ងន់ទេ មកគឺត្រូវបាត់ខ្លួនអញ្ចឹង តែម្តង ហើយបើបាត់ខ្លួន គ្មានពេលវិលវិញទេ ។

ភារិទ្ធៈ ហើយអញ្ចឹងពូ អាការដែលគេបញ្ជារហ្នឹង មានពីលើឬក៏?

ឌុចៈ រឿងហ្នឹងមិនមែនត្រឹមហ្នឹងទេអូន មិនមែនត្រឹមហ្នឹងធ្វើកើតទេ ហើយម្យ៉ាងទៀត តំណាត មក គេថាខ្សែបណ្តោយរបស់គេ ខ្សែរយៈរបស់គេ អាហ្នឹងគេថា ពួកបក្សជនគេ កាលពី ជំនាន់ហ្នឹង មានពួកបក្សជនគេ នៅក្នុងសុទ្ធតែមេ មេគេធំ សំងាត់ដូចថា មេធំ គេអីហ្នឹង សុទ្ធតែបក្សជនគេហើយ គេសំងាត់ៗ គេប្រជុំ គេដែលអោយយើងដឹង តែយើងដើរ ជិតមិនបានផង ។

ភារិទ្ធៈ អូ!

ឌុចៈ អញ្ចឹងបានថាការងារហ្នឹង វាលំបាក ខ្ញុំមិនចេះទេ ខ្ញុំមិនយល់ ទោះបីមកដេកគិតរាល់ថ្ងៃ គិតមិនយល់ មិនយល់ត្រង់ថា នៅក្នុងមួយកង វារាប់រយនាក់ មេតែមួយអញ្ចឹង ដើរទៅ ហើយមេហ្នឹង មិនចេះអក្សរមួយបៀកផង សូម្បីតែនិយាយហ្នឹង អត់មានចេះអត់ដឹងស្អី

ផង អត់ចេះស្អីទេ គឺអ្នកល្ងង់សុទ្ធ ចេះតែធ្វើ គឺអ្នកអត់ចេះ ហើយអវិជ្ជាហ្នឹងគឺវាធ្វើតែម្តង ។

ភារិទ្ធៈ ម៉េចបានគេប្រើមនុស្ស?

ឌុចៈ អញ្ចឹងបានខ្ញុំថា វាមិនដឹងដែរ វាមិនដឹងថាអាពីលើហ្នឹង គេប្រើយ៉ាងម៉េច ខ្ញុំវាអត់ដឹង វារកសន្និដ្ឋានមិនត្រូវទេ អត់យល់ទេ ខ្ញុំអត់ អត់យល់ទេ ខ្ញុំអត់យល់មែន ។

ភារិទ្ធៈ ហើយចុះពូ កាលពូនៅយាមគុកហ្នឹង មានដែលឃើញអ្នកទោសរត់ចេញអីដែររឺអត់?

ឌុចៈ អត់ទេ អត់មានរត់ទេ រត់ឯណាទៅអូនឯង អូនឯងកុំសង្ស័យថា រឿងរត់អីទៅដល់យ៉ាងយូរមួយអាទិត្យហ្នឹង អត់ទេ អត់រត់ទេអូន ទៅរត់ម៉េចរួចអូន មួយអាទិត្យដែលអត់បាយ អូនឯងទៅណារួច សូម្បីតែលើកដៃ លើកមិនរួចផង ហើយធ្វើម៉េចបានរត់រួច ធ្វើម៉េចមានកំលាំងរត់ យ៉ាងយូរហ្នឹងមួយអាទិត្យ ត្រូវដេកនៅស្ងួលហ្នឹង ទាំងគេទាំងយើងដាច់ពោះបាយមួយអាទិត្យ ។

ភារិទ្ធៈ ហើយចុះកាលហ្នឹង ប្រជាជនធ្វើស្រែអីបានដែរ?

ឌុចៈ តែប្រជាជនដើរជិតរបងហ្នឹង មិនបានផង អត់បានទេណា របងខាងក្រៅព័ទ្ធមួយហិចតា ៤ជ្រុង ហើយប្រជាជនបានតែក្រៅ តែអើតមើលមិនបានអើតផង សួរប្រជាជន ជិតហ្នឹងដែលបានទៅអើត ទៅអើតមើលទេ

ភារិទ្ធៈ តែខ្ញុំចង់សួរអញ្ចេះ កាលហ្នឹងក្រែងប្រជាជនធ្វើបានដែរអេ ឬក៏យ៉ាងម៉េច?

ឌុចៈ ប្រជាជនខ្ញុំធ្វើស្រូវ ។

ភារិទ្ធៈ បាទ!

ឌុចៈ ធ្វើបានអូន ប៉ុន្តែសូម្បីតែអ្នកធ្វើហ្នឹង មិនបានហូបផង ទំរាំតែអ្នកដេកនៅក្នុងគុកហ្នឹងយកទៅអោយស៊ីទៀត ដូចវាអត់ទេ អត់ អ្នកខំធ្វើហ្នឹងអា៎ មួយហិចតាដល់៣តោន ធ្វើចង់ស្លាប់ បបរដាក់ឆ្នាំងខ្ទះអា៎ បើសិនជារស់ទាន់ជំនាន់ហ្នឹង បានដឹងថាឈឺចាប់ ការឈឺចាប់ហ្នឹងយ៉ាងម៉េចដឹងហើយ ហើយក្មេងសម័យឥលូវ អាយុស្រករអូន ៣០ជាង អត់ទាន់ទេណា ។

ភារិទ្ធៈ អត់ទាន់ទេ?

ឌុចៈ អត់ទាន់ទេ លីតែគេថាទេ ហើយវាមិនដែល ហើយអត់ជឿទៀត មើលខ្ញុំនិយាយឥលូវ អត់ជឿទេ ។

ភារិទ្ធៈ បាទ!

ឌុចៈ អត់ជឿត្រង់ថាស្រូវធ្វើបាន អូនឯងដាំដំឡូងក្បែរផ្ទះ ឥលូវផ្ទះគេធ្វើអោយអូនឯងដាំក្បែរផ្ទះដាំទៅ ប្រជាជនដាំទៅ ដាំបានទាំងអស់ ប៉ុន្តែអូនឯងគាស់បានមួយគុម្ពរឿងឥលូវហើយ ឆាប់ហើយនេះ បាត់បណ្តូលមួយគុម្ព ។

ភារិទ្ធៈ អូ!

ឌុចៈ អញ្ចឹងបានថា បើខ្ញុំនិយាយអូនឯងអត់ជឿទេ បើសិន សួរអ្នកដែលថា ធ្លាប់កាត់ជំនាន់ហ្នឹងតែម្តងបានដឹងថា វាដូរចត់ ក៏វាល្វីង វាផ្អែមយ៉ាងម៉េច ដឹងហើយ ។

ភារិទ្ធៈ ហើយចុះពូហូបចុកអីយ៉ាងម៉េចដែរ ពូធ្វើឈ្លបធ្វើ?

ឌុចៈ ខ្ញុំហូបចុកធម្មតា មានបបរ បបរអញ្ចឹងទៅ បាយ បាយអញ្ចឹងទៅ អាហ្នឹងតាមអង្ករគេយក មកអោយ ។

ភារិទ្ធៈ បាទ!

ឌុចៈ អង្ករគេយកមកអោយ ដូចថា កងទ័ពអញ្ចឹង គេមានធ្វើស្រែឯណា គេយកអង្ករដល់ខែមិនដល់ខែទេ នៅក្នុងមួយថ្ងៃគេទៅបើកមួយដង ទៅយកអង្ករ គេចុងភៅហ្នឹងទៅយកឥលូវឧទាហរណ៍ថា គ្នាយើងសាមសិបនាក់ ហើយក៏១០នាក់អញ្ចឹង ពីរនាក់មួយកំប៉ុងបើថាសាមសិបនាក់ ១៥កំប៉ុងអញ្ចឹងទៅ នៅក្នុងមួយថ្ងៃ ។

ភារិទ្ធៈ អូ!

ឌុចៈ ស្អែកឡើងទៅទៀតទៅ អ្នកសេដ្ឋកិច្ចគឺរត់រហូត ។

ភារិទ្ធៈ បាទ !

ឌុចៈ មិនមែនទៅនៅមួយខែ បើកមួយដងអីអត់ទេ ហើយម្ហូបយើងដោះស្រាយខ្លួនឯងទៅយើងរកទៅក្តាមខ្យងហ្នឹង មានដង្កូវណាទៅទិញ ហើយយើងទៅចិញ្ចឹមអីបាននឹងគេអត់ប៉ុននិយាយពីរឿងហ្នឹង បើសិនជាមកដល់ត្រឹមស្រុកខ្ញុំដឹងខ្លះ ដល់តែចាស់ជាងខ្ញុំបានដឹងដែលអាយុច្រើនជាងខ្ញុំណា កាលពីជំនាន់ហ្នឹងគេត្រឹមអាយុ២០ឆ្នាំ គេអាចដឹងពីសកម្មភាពអីហ្នឹង គេក្តាប់បានជុំ ខួរក្បាលគេវាចាស់ទៀត បើខ្ញុំអត់ដឹងទេ ដឹងតែពីលិច លិច កើត

កើត បើមិនធ្វើខ្លាចគេធ្វើបាប បើខ្លាច ខ្លាចពេកហើយ ប៉ុន្តែធ្វើយ៉ាងម៉េច ដើម្បីរស់ចេះតែទៅតាមគេទៅ ។

ភារិទ្ធៈ ហើយចុះជំនាន់នោះគេមានប្រើអោយសម្លាប់មនុស្សទេ?

ឌុចៈ មិនមែនទេ ជំនាន់នោះមិនមែនដែលថា ឥលូវអូនឯងនៅតាមភូមិ តាមឃុំ ឬមួយថាអូនឯងស្គាល់ខ្ញុំអញ្ចឹងចង់រកតែសម្លាប់មនុស្សហ្នឹងអញ្ចឹង គេអត់ទេ គេអត់ធ្វើអញ្ចឹងទេគេមានលក្ខណៈគេ គេដល់តែជំនិតរបស់គេខ្លាំងណាស់ បានគេអោយចូលទៅ បានតែគេអោយចូលទៅអញ្ចឹង វេនចូលតែម្តង គេដឹងតែម្តង ហើយបើថាយើងគ្រាន់តែថា នេះស្គាល់គ្នាអានេះក៏ធ្លាប់នៅជាមួយគ្នាដែរ អត់ទេសូម្បីតែម៉ែហ្នឹង គេមិនអោយទៅជិតផង ។

ភារិទ្ធៈ ហើយចុះម៉េចបានជាខ្មែរសម្លាប់ខ្មែរជំនាន់នោះ?

ឌុចៈ ខ្ញុំ ដូចជាយល់អញ្ចេះអូន សម័យនោះ មិនមែនចង់និយាយថា រឿងនេះជារឿងនយោបាយ ឬមួយក៏ជារឿង ខ្ញុំថាមកពីអ្នកដឹកនាំ យល់ឃើញដោយខ្លួនឯងមិនស្វែងយល់ពីគេគ្រប់គ្នា យល់ឃើញថាដូចអូនឯងអញ្ចឹង នែ អញធ្វើអញ្ចេះទៅត្រូវ អញឈ្នះ អញធ្វើអញ្ចេះទៅអញពូកែជាងគេ អញខ្លាំងជាងគេ អញមិនប្រើស្អីទាំងអស់ ដូចជំនាន់ប៉ុលពតអញ្ចឹង អូនឯងមើលដឹកប្រឡាយមិនប្រើគ្រឿងចក្រមួយដុំ យកទៅតែកំលាំងមនុស្សយកទៅសម្លាប់ង៉ាប់មនុស្សទាំងវាល ទាំងវាលស្រូវធ្វើបានអត់មានអោយស៊ីទេ ហើយមិនដឹងជាស្រូវហ្នឹងយកទៅណាទៀត ឥលូវសួរថាធ្វើហ្នឹង ដឹងថាស្រូវយកទៅណាទេ អត់ដឹងរលីង ស្រាប់តែអស់តែម្តងអូន អស់តែម្តង ហើយដូចថាខ្ញុំម្នាក់ឃើញថា អស់ស្រូវម៉េចអស់ស្រូវហើយ សួរង៉ាប់ឥលូវហើយ សួរបាត់ខ្លួនឥលូវហើយ ។

ភារិទ្ធៈ ហើយចុះពូកាលហ្នឹងមានធ្វើអីខុសទេ?

ឌុចៈ ខ្ញុំ ដូចជាអត់ទេ អូន ខ្ញុំមិនដែលធ្វើអី អោយគេថា ចាប់កំហុសខ្ញុំ ប៉ុន្តែនៅក្នុងអារម្មណ៍គេគេមើលខ្ញុំថាដូចបន្ទាអញ្ចឹង អាហ្នឹងខ្ញុំយល់ ។

ភារិទ្ធៈ បាទ!

ឌុចៈ ព្រោះខ្ញុំ ខ្ញុំកាលពីជំនាន់ហ្នឹង ខ្ញុំចេះអក្សរ ខ្ញុំរៀនបានកុងគួរអូន ។

ភារិទ្ធៈ បាទ!

ឌុចៈ ខ្ញុំចេះអក្សរ អញ្ចឹងដូចថាគេធ្វើស្អីក៏ដោយសារ អោយតែធ្វើហួសហេតុទៅ ខ្ញុំចេះតែនិយាយថា ឯងកុំប្រើវាខ្លាំង ក្មេងៗធ្វើបាប ក៏គេមើលលើមើលក្រោមដែរ ហើយខ្ញុំទៅណាអត់រួចមកពីអញ្ចឹង កុំអីកាលពីជំនាន់ហ្នឹង គេអោយខ្ញុំឡើងធំ ធ្វើធំអាណាបានបំរុងអោយឡើងធំ តែឡើងអី ប៉ុន្តែទៅអត់រួចទេ គេមកធ្វើប្រវត្តិរូបខ្ញុំ គេស្រាវជ្រាវទៅម៉ែឪពាក់ព័ន្ធទាំងអស់ ជីដូនមួយគេយកទៅសម្លាប់ ជីដូនមួយធ្វើទាហាននៅភ្នំពេញ បងខ្ញុំ

ភារិទ្ធៈ ឈ្មោះអី?

ឌុចៈ ឈ្មោះឃឿនៗ

ភារិទ្ធៈ អូ!

ឌុចៈ ហើយបងមួយទៀត គេចខ្លួនចេញទៅក្រៅប្រទេសទៅ ហើយមាខ្ញុំ អ៊ំខ្ញុំបង្កើតធ្វើទាហាន ១៧, ១៧មក មកហ្នឹងដែរ មកជាមួយម៉ែខ្ញុំដែរ ហើយចុះគាត់មានបងប្អូនតែពីរនាក់ៗ

ភារិទ្ធៈ អញ្ចឹង ?

ឌុចៈ អញ្ចឹងបានថា វាលំបាកដែរ ប៉ុនដល់ខ្ញុំ ដំណើរគេថា រុយទុំ បណ្តោយទឹកទៅៗ

ភារិទ្ធៈ បាទ!

ឌុចៈ បណ្តោយៗ គេទៅ បានរស់ដែរ អញ្ចឹងបានជំនាន់នោះ អ្នករស់ៗ

**Side B:**

ភារិទ្ធៈ អញ្ចឹងពូ ខ្ញុំចង់សួរនេះទៀត កាលពីវៀតណាមវាយចូល កាលពី៧៩ ពូមានដឹងថាអ្នកទោសនៅរស់ប៉ុន្មាននាក់ដែរ?

ឌុចៈ អត់ដឹងទេ ខ្ញុំចេញហើយៗ

ភារិទ្ធៈ អូ!

ឌុចៈ ខ្ញុំចេញមុនទៅទៀត ៗ

ភារិទ្ធៈ អូ ចេញមុន ?

ឌុចៈ ខ្ញុំកាលវៀតណាមវាយចូលមក ខ្ញុំទៅនៅគេអោយទៅនៅស្រុកអីទេ កោះអណ្តែតស្រុកគេទេ ខ្ញុំភ្លេចឈ្មោះហើយៗ

ភារិទ្ធៈ ស្រុកកោះអណ្តែតហ្នឹង?

ឌុចៈ ទៅនៅកោះអណ្តែត ស្រុកកោះអណ្តែតហ្នឹង ប៉ុន្តែមិនដឹងឃុំអី ភូមិអីៗ

ភារិទ្ធៈ បាទ !

ឌុចៈ នៅហ្នឹងកាលពីជំនាន់ហ្នឹង ។

ភារិទ្ធៈ អូ!

ឌុចៈ ហើយដល់តែវៀតណាមចូលមក បុកមក កាលហ្នឹងចូលដល់ភ្នំពេញហើយនិងបានខ្ញុំដកអត់ទាន់ ចូលមកដល់ព្រៃលើនេះ ។

ភារិទ្ធៈ បាទ!

ឌុចៈ បើវៀតណាមព័ទ្ធជាប់មកព្រៃលើហ្នឹង អាហ្នឹងនៅកង នៅខ្ញុំ នៅ១៣វិញហើយហ្នឹងកាលហ្នឹង បងអ្នក កងវរយ ដឹងតែត្រឹមប៉ុណ្ណឹងទេ តែមេធំៗ អត់ដឹងទេបាត់អស់ហើយមិនដឹងទៅណាទេ បាត់អស់ហើយ ។

ភារិទ្ធៈ ពួកដែលថា នៅត្រើនៅ?

ឌុចៈ ហ្នឹងហើយពួកហ្នឹង ។

ភារិទ្ធៈ អូ!

ឌុចៈ ពួក កាលហ្នឹងគាត់មេបញ្ជាការ កងពិសេស ។

ភារិទ្ធៈ កងពិសេសហ្នឹងយ៉ាងម៉េច?

ឌុចៈ កងពិសេសហ្នឹងអញ្ចេះអូន កងពិសេសហ្នឹង មិនមែនបានន័យថា អ្នកខ្លាំងជាងគេ អ្នកហ៊ានជាគេទេជំនាន់នោះ ឧទាហរណ៍ថា ពួកថ្មើរជើងគេចែក២-៣សណ្ឋានហ្នឹង កងថ្មើរជើង គេមានអញ្ចឹងទៅណា ដូចថា ផ្លូវបន្ទាយមួយអញ្ចឹងទៅណា ផ្លូវបន្ទាយមួយអញ្ចឹង ។ ដូចថាបន្ទាយនៅអន្លុងតាសោម គេទៅឡោមព័ទ្ធ ហើយយើងកងពិសេសហ្នឹង គឺកងជំនួយ កាលណាគេបាញ់ព្រោលអញ្ចឹងទៅណា ផ្ទុះអាវុធអញ្ចឹងទៅ គេហៅយើងហើយហៅកងពិសេសទៅជំនួយ ហើយយើងទៅជំនួយកងពិសេស ហើយបើថា ត្រង់កន្លែងថាតឹង ថ្មើរជើងទៅមិនរួច គេអោយពួកពិសេសហ្នឹងចូលហើយ ហើយមានតែការប៉ុណ្ណឹងទេ បើថាវាយប៉ុណ្ណឹងហើយ ចេញទៅ យើងមកសំរាកវិញរាប់អាទិត្យ រាប់ខែ ទំរាំមានកន្លែងណាទៀត បានទៅទៀត ។

ភារិទ្ធៈ ពូភៀសខ្លួនទៅដល់ណាដែរ ពេលវៀតណាមវាយចូល?

ឌុចៈ ខ្ញុំមកហ្នឹង ខ្ញុំរត់មកដល់ត្រឹមនេះទេ លិច ខាងជើង ផ្លូវជាតិខាងត្បូង ផ្លូវជាតិលេខ៤ ទេណា អត់ឆ្លងផ្លូវជាតិផង ត្រឹមហ្នឹង ហើយមកវិញមក។

ភារិទ្ធៈ អូ ហើយមកភូមិវិញអេអី?

ឌុចៈ បាទ! មកនៅភូមិវិញ ខ្ញុំចូលមក ចូលមកអញ្ចេះ ខ្ញុំចូលមកអញ្ចេះ កាលហ្នឹងជំនាញការវៀតណាម ចូលមកគេហៅខ្ញុំម្តងទៀត ចូលមក ចូលមកអញ្ចឹង ក្រាំងតាចាន់ហ្នឹង ចូលមកតុក។ ។ ឌុច ថាឌុចហ្នឹង មេអាហ្នឹង ហើយដល់តែសួរខ្ញុំ ខ្ញុំអត់ដឹង ខ្ញុំថា ឌុចមែនបាន អាប៉ិមួយនោះខ្មែរ គាត់ថាមិនមែនទេ ឌុចនោះស ហើយចាស់ទេ អញ្ចេះមិនមែនឌុចនេះក្មេងទេអញ្ចេះ ជំនាញការគេសំឡុតខ្ញុំខ្លាំង សំឡុតខ្ញុំកាលហ្នឹង ហើយខ្ញុំមិនដឹងថាឆ្លើយថាយ៉ាងម៉េចអត់ចេះបងឯង ហើយឆ្លើយថាម៉េច បើអត់ដឹង ហើយគេថាឌុចហ្នឹងប្រធានស្រុក ខ្ញុំថាមាន ឌុចហ្នឹង តែឌុចហ្នឹង សហើយចាស់ ហើយបានអាប៉ិមួយ ថា បើគេមកមើលខ្ញុំ សួរថានៅហ្នឹង ថានៅលាយបូ មិនមែនទេ ប៉ុហ្នឹងថាមិនមែនទេណា បានគេលែងខ្ញុំ ហើយ បានគេធ្វើសំបុត្រធ្វើអីអោយមកផ្ទះ មកសំបែងមក។

ភារិទ្ធៈ អូ!

ឌុចៈ អាហ្នឹងកុំអី គេយកទៅញ៉ាបាងបាត់ កាលហ្នឹងកុំអីគេយកទៅដាក់គុកញ៉ាំងបាង។

ភារិទ្ធៈ អូ!

ឌុចៈ គេប្រឡំឈ្មោះ ហើយអាប៉ិជំនាញហ្នឹងមួយទៀត ខ្មែរហ្នឹង បានស្គាល់ច្បាស់ គាត់ថាគាត់ស្គាល់ច្បាស់ គាត់ថាមិនមែនទេ ឌុចហ្នឹង ស រាងល្អិត ថ្ងាស ថាធៀអញ្ចេះអាហ្នឹងត្រូវរបស់គាត់មែន គាត់ថាត្រូវរបស់គាត់មែន ប៉ុហ្នឹងស ហើយរាងល្អិត។

ភារិទ្ធៈ ពូធ្លាប់ស្គាល់?

ឌុចៈ បាទ!

ភារិទ្ធៈ ពូយាមកាល ម៉េចបានឃើញគាត់?

ឌុចៈ ហើយចុះឃើញ ទៅហ្នឹង ស តាធៀ សក់ឈរ សក់ឈរដូចអូនអញ្ចឹង ប៉ុន្តែរាង ថ្ងាសតាធៀបន្តិចហើយ ប៉ុន្តែស អាប៉ិហ្នឹង ថារៀនជ្រៅជ្រះ ថារៀន អត់ដឹង មិនដឹងស្រុកកំណើតនៅឯណាទេ។

ភារិទ្ធៈ អត់ដែលជួបគាត់ទេ តាំងពីបែក?

ឌុចៈ យើងគ្រាន់តែឃើញថា គេថាប៉ុហ្នឹង ឈ្មោះប៉ុឌុចហើយគ្រាន់តែប៉ុណ្ណឹង បើថាយើងបាន ឈរជិតគេ អាប៉ុហ្នឹង ប្រជុយក៏មិនដឹងដែរ គ្រាន់តែមើលឃើញហ្នឹង ។

ភារិទ្ធៈ ហើយចុះពូឆ្ងល់កាត់ជំនាន់បីឆ្នាំហ្នឹង ពូយល់ថាយ៉ាងម៉េចដែរ?

ឌុចៈ ខ្ញុំថារឿងរ៉ាវហ្នឹង វារឿងវាបាត់យូរហើយ ប៉ុន្តែបើយើងមិនលើករឿងហ្នឹងមកនិយាយ ក្មេងវាអត់ដឹង ហើយបើមិនទុកជាឯកសារសំរាប់កូនៗ ឬចៅទួតតទៅក្រោយទៀតឲ្យ ដឹងថាពីជំនាន់ដែលថាកាប់សម្លាប់ពីរបបខ្មែរក្រហមហ្នឹងវាយ៉ាងម៉េច អីយ៉ាងម៉េចក៏អត់ដឹង ដែរ អញ្ចឹងរបបហ្នឹង ដែលគេថាស្អប់ខ្ពើមគ្រប់គ្នាហ្នឹង គួរណាស់តែគេកាត់ទោសមែន ខុស ។

ភារិទ្ធៈ ហើយចុះពូធ្លាប់លឺពី តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ឌុចៈ ខ្ញុំ លឺអូន ខ្ញុំស្តាប់លឺ ។

ភារិទ្ធៈ លឺតាំងពីពេលណាមក?

ឌុចៈ យូរហើយដែរហើយ តុលាការកាត់ទោសហ្នឹង ប៉ុន្តែខ្ញុំដូចជាឆ្ងល់បន្តិច ត្រង់ខ្ញុំឆ្ងល់ ត្រង់ រាជរដ្ឋាភិបាលយើង បើសិនជាយើង បុគ្គលទាំងអស់ហ្នឹង អោយកាត់ទោសតែម្តង បានដឹងតែម្តង បានជឿថាយុត្តិធម៌តែម្តង បើថាអោយខ្មែរគ្នាឯងកាត់ទោស ខ្ញុំនៅថា នៅមិនទាន់ទុកចិត្តត្រង់ សូម្បីតែមេដឹកនាំយើងធំៗ សព្វថ្ងៃហ្នឹងមិនធំថ្នាក់កំពូលទេ ថ្នាក់ ក្រោមៗហ្នឹង សុទ្ធតែពីខ្មែរហ្នឹងមកទាំងអស់ដែរ ខ្ញុំនឹកឃើញ ក្រែងល៉ាវាមិនយុត្តិធម៌ ចំពោះអ្នករងគ្រោះ ។

ភារិទ្ធៈ បាទ!

ឌុចៈ ហើយប្រជាជនយើងចាំតែមើលទេ ចាំតែមើលគេកាត់ទោសវារបៀបម៉េច អោយ តុលាការយុត្តិធម៌មក វាត្រឹមត្រូវហើយ ។

ភារិទ្ធៈ តុលាការដែលគេប្រុងបង្កើតហ្នឹង គឺតុលាការចំរុះ រវាងអង្គការសហប្រជាជាតិ ហើយ និងរាជរដ្ឋាភិបាលកម្ពុជា តើពូមានដឹង?

ឌុចៈ ខ្ញុំដឹង ខ្ញុំដឹង ។

ភារិទ្ធៈ ហើយបើសិនជាតុលាការហ្នឹងកើតមាន តើពូយល់ថាតុលាការហ្នឹងអាចផ្តល់យុត្តិធម៌ សំរាប់អ្នកដែលរងគ្រោះជំនាន់ហ្នឹងបានដែរឬអត់?

ឌុចៈ ខ្ញុំយល់ឃើញថា បើសិនជាអន្តរជាតិមកកាត់ទោស អាហ្នឹងខ្ញុំជឿថាយុត្តិធម៌ជាង ហើយបើសិនជាចំរុះគ្នា អាហ្នឹងក៏ខ្ញុំមិនទាន់ហ៊ានសន្និដ្ឋានថាយ៉ាងម៉េច គឺចាំមើលសិនដែរទៅ ។

ភារិទ្ធៈ បាទ!

ឌុចៈ អាហ្នឹងគ្រាន់តែប៉ុណ្ណឹង ។

ភារិទ្ធៈ ពូ មេដឹកនាំខ្មែរក្រហមដែលដឹកនាំអោយមានការសម្លាប់មនុស្ស ពូមានធ្លាប់លឺ ធ្លាប់ស្គាល់ ?

ឌុចៈ លឺតែឈ្មោះ

ភារិទ្ធៈ ឈ្មោះអីខ្លះទៅ?

ឌុចៈ ប៉ុល ពត, តាម៉ុក, តាអី ខៀវ សំផន, នួន ជា អាហ្នឹងយើងស្តាប់បានតែប៉ុណ្ណឹងទេណា ប៉ុន្តែគ្រាន់តែឃើញមុខ មិនដឹងមុខអាម៉េចទៀត ។

ភារិទ្ធៈ ហើយចុះប៉ុល ពតហ្នឹងធ្វើអី? ខៀវ សំផនហ្នឹងធ្វើអី? នួន ជា ហ្នឹងធ្វើអី? តាម៉ុកហ្នឹងធ្វើអី?

ឌុចៈ កាលពីជំនាន់ហ្នឹង ប៉ុល ពត លេខាបក្ស, ខៀវសំផនប្រធានគណៈសភារដ្ឋ,

ភារិទ្ធៈ អូ!

ឌុចៈ នួន ជា ប្រធានសភា អាហ្នឹងអញ្ចឹង?

ភារិទ្ធៈ បាទ!

ឌុចៈ ហើយតាម៉ុកប្រធានភូមិភាគ ។

ភារិទ្ធៈ អូ ភូមិភាគអីគេ?

ឌុចៈ ភូមិភាគនិរតីហ្នឹង ។

ភារិទ្ធៈ ហើយចុះក្រៅពីហ្នឹងទៀត?

ឌុចៈ ក្រៅពីហ្នឹងអត់ស្គាល់

ភារិទ្ធៈ អូ អៀង សារី អី មានធ្លាប់?

ឌុចៈ អៀង សារី ក្រសួងការបរទេស ។

ភារិទ្ធៈ ហើយចុះសុន សេនអី?

ឌុចៈ សុន សេន លឺឈ្មោះដែរ ប៉ុន្តែមិនដឹងខាងអីទេនេះ អត់ចាំទេ អត់ចាំ ។

ភារិទ្ធៈ ហើយចុះពួមេដឹកនាំដែលពូស្គាល់ទាំងអស់ មានដឹងថានៅរស់ប៉ុន្មាន ស្លាប់នរណាគេខ្លះ?

ឌុចៈ អត់ដឹងទេ គេស្លាប់គេរស់នេះ អ្នកធំៗហ្នឹង អត់ដឹងទេអូន សូម្បីតែជំនាន់ហ្នឹង មេភូមិ មេឃុំហ្នឹងក៏វាបាត់ខ្លួនអស់ដែរណា ហើយលឺតែតាមគេទេ ព្រោះខ្ញុំមិនសូវដែល បាននៅផ្ទះទេ កាលពីជំនាន់ហ្នឹងអត់នៅផ្ទះទេ គេអោយទៅនៅរហូត តែម៉ែឪខ្ញុំអត់ដែលបាន មកជួបមុខផង ។

ភារិទ្ធៈ ហើយចុះពួតុលាការហ្នឹង គេប្រុងកាត់ទោស តែមេៗ ហើយនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ។

ឌុចៈ បាទ!

ភារិទ្ធៈ ដូចថា អ្នកដែលសម្លាប់មនុស្សជំនាន់ហ្នឹង តាមមើលទៅដូចថា ថ្នាក់ក្រោមៗទេ ?

ឌុចៈ ខ្ញុំយល់អញ្ចឹងដែរ ។

ភារិទ្ធៈ តើពូយល់ថាកាត់អញ្ចឹងគ្រប់គ្រាន់ដែរឬអត់?

ឌុចៈ មិន ខ្ញុំយល់អញ្ចេះអូន គំនិតខ្ញុំយល់ទេណា វាបើសិនជាកាត់ទោស តែមេធំៗអ្នកផ្ទាល់ ដែលមិនបានយកទៅកាត់ទោសនេះ អ្នកសម្លាប់ផ្ទាល់ ឧទាហរណ៍ថា អូនឯងបញ្ជារខ្ញុំ ។

ភារិទ្ធៈ បាទ!

ឌុចៈ អូនឯងចុះ ខ្ញុំអ្នកសម្លាប់ បើអញ្ចឹង ខ្ញុំក៏ត្រូវមានទោស បើថាមិនដល់កំពូលក៏វាបន្ទាប់ពី អូនឯងដែរ បើថាអ្នកបញ្ជារ វា១០ឆ្នាំ អ្នកអនុវត្តផ្ទាល់ហ្នឹង វាតាមច្បាប់ទៅចុះ ។

ភារិទ្ធៈ បាទ!

ឌុចៈ ច្បាប់វាត្រូវធ្វើយ៉ាងម៉េចទៀត ប៉ុន្តែ ខ្ញុំចង់ធ្វើអញ្ចឹង អាហ្នឹងបានយើងអស់ចិត្ត

ភារិទ្ធៈ បាទ!

ឌុចៈ ហើយបើសិនជា អាហ្នឹងវាមានពីរសណ្ឋានអញ្ចេះទៀត មួយទៀត ដូចថាអូនឯងអ្នក បញ្ជារសម្លាប់ ។

ភារិទ្ធៈ បាទ!

ឌុចៈ មួយទៀត អត់ទេ ខ្ញុំខឹងអានេះ ខ្ញុំថ្នាក់ក្រោមទេណា ប៉ុន្តែខ្ញុំខឹងអានោះ ខ្ញុំទៅសម្លាប់ អានោះសម្លាប់ចោលបាត់ រឿងហ្នឹង ហើយខ្ញុំអ្នកសម្លាប់ហ្នឹង ខ្ញុំរួចខ្លួន តាមពិតអូនឯង បញ្ជារអោយសម្លាប់ម្នាក់ទេ តែខ្ញុំសម្លាប់បីនាក់ ។

ភារិទ្ធៈ អូ!

ឌុចៈ វាអញ្ចឹង អញ្ចឹងអាហ្នឹង កាត់ទោសអញ្ចឹង វាដូចថា ខ្ញុំថាវាដូចជាស្រាច់តែពិចារណាទៅ ពិចារណាមើលយើងទាំងអស់គ្នា ។

ភារិទ្ធៈ ហើយចុះបើសិនជាការកាត់ទោសត្រឹមតែថ្នាក់ក្រោមអញ្ចឹង ពូយល់ថាវាអាចប៉ះពាល់ដល់ ធ្វើអោយសង្គមយើងវាបែកបាក់គ្នាដែរ អ្នកដែលសម្ងាប់វាមាន អាចមានច្រើន ។

ឌុចៈ មានច្រើននេះខ្ញុំ បើសិនជា ខ្ញុំមិនអាចយល់ស៊ីជំរៅទេអូន ពិបាកសន្និដ្ឋានមិនអាចនិយាយ កើត ពួកយើងមិនសូវដឹងពីរឿងច្បាប់ទំលាប់ដូចថា ឥលូវច្បាប់កាត់ទោសហ្នឹងវារបៀប ម៉េច ព្រោះយើងសព្វថ្ងៃនេះ របបប្រជាធិបតេយ្យមែន បានដូចជាត្រឹមតែនិយាយប្រជា ធិបតេយ្យបានត្រឹមតែនិយាយ ខ្ញុំមើលសព្វថ្ងៃទៅ អញ្ចឹងមានន័យថា តូចស៊ីតាមតូច ធំ ស៊ីតាមធំ ដដែលហ្នឹង តុលាការសព្វថ្ងៃ អាណាមានលុយ គឺឈ្នះអញ្ចឹងតែម្តង ។

ភារិទ្ធៈ អូ!

ឌុចៈ អញ្ចឹងបានខ្ញុំរកទុកចិត្តមិនឃើញ អញ្ចឹងបានរឿងអី ខ្ញុំមិនសូវគិតគូរ ។

ភារិទ្ធៈ ហើយចុះធ្វើម៉េចដើម្បីអោយមានយុត្តិធម៌ទៅថ្ងៃមុខ?

ឌុចៈ ខ្ញុំចង់និយាយថា ដើម្បីយុត្តិធម៌សង្គម យើងទាំងអស់ហ្នឹងបានសុខ យើងទាំងអស់គ្នា ហ្នឹងមានសិទ្ធសេរី ប៉ុនៗគ្នាទាំងអស់ និងមានសិទ្ធិនិយាយស្តីអីស្មើគ្នាទាល់តែយើង រស់នៅ ក្រោមដំបូលច្បាប់តែមួយ យកច្បាប់ជាធំតែម្តង ឧទាហរណ៍ថា ប្រទេសយើងមួយមាន រដ្ឋធម្មនុញ្ញចែងហើយអញ្ចឹង ហើយបើថាយើងអត់ណា អ្នកដែលល្ងង់ អ្នកមិនចេះនៅក្នុង មួយផ្ទះ ក៏មានអ្នកចេះអក្សរមួយដែរ យករដ្ឋធម្មនុញ្ញមកចែកអោយ ទុកអោយអានទៅ ឯងធ្វើខុសអី បើកអាហ្នឹងទៅ ឯងដឹងខុសអាហ្នឹង ជាប់គុកខ្លួនឯងទៅ ខ្ញុំចង់អញ្ចឹងវិញ វាស្រួលជាង អ្នកធ្វើខុស ហើយឥលូវអូនឯងធ្វើម៉េច បើអ្នកខុស មិនដឹងខុស អ្នកត្រូវ មិនដឹងត្រូវ ខ្ញុំមិនដែលមានរឿងរ៉ាវអី នៅក្នុងសង្គមនេះ ហើយមិនដែលថាមានវិប្បសារី អី ជាមួយអ្នកណាទេ ប៉ុន្តែខ្ញុំគ្រាន់តែមើលទិដ្ឋភាពខាងក្រៅ ។

ភារិទ្ធៈ អូ!

ឌុចៈ ខ្ញុំមើលឃើញគេ ខ្ញុំអនិច្ចា ហើយម្យ៉ាងទៀតខ្ញុំ ដូចថាវាចេះតែខាំមាត់ សង្កត់ចិត្តអញ្ចឹង ទៅ កាលណាគេថា ហើយគេបោះពាក្យស្លោកមួយគេនិយាយទៀតថា ចេះគេខឹង ដឹងគេ

ស្អប់ យើងចេះពេកទៅគេខឹង ហើយយើងដឹងច្រើនទៅនាំតែគេស្អប់ អានេះវាអញ្ចេះ ពាក្យស្លោកវាមានអញ្ចឹងមក ហើយដល់តែហើយយើងរកនិយាយមិនកើត ។

ភារិទ្ធៈ ហើយចុះពូដូចកាលពីជំនាន់ខ្មែរក្រហម ពូមានបាត់បង់បងប្អូនអីអញ្ចឹង ដូចជាមកដល់ឥលូវ ឬក៏ទៅថ្ងៃមុខ ពូមានដឹងថា អ្នកដែលសម្លាប់បងប្អូនពូហ្នឹង នៅរស់ ពូចង់សងសឹកគេដែរ?

ឌុចៈ មិនទេ អូន អានេះបើបុគ្គលម្នាក់ មកសងសឹកនឹងបុគ្គលម្នាក់ ធ្វើនេះវាអត់យុត្តិធម៌ទេ អ្នកដែលទៅសម្លាប់គេហ្នឹង ក៏ចេតនាដែរ បានខ្ញុំយល់ឃើញអញ្ចឹង ព្រោះឃើញហើយ អ្នកដែលទៅសម្លាប់គេហ្នឹង មិនមែនគ្មានចេតនាទេ គឺដោយសារគេរុញ គេទាញទៅហ្នឹង នោះឯងទៅ ឯងមិនទៅ អាហ្នឹងបានថាវាអញ្ចឹងអាអូន វាពិបាកអាណា ខ្ញុំពិបាកសន្និដ្ឋាន បានថាខ្ញុំ ខ្ញុំមិនបន្ទោសអ្នកសម្លាប់ទេ បើថាគេទោស១០ឆ្នាំ អ្នកឯងសម្លាប់ថាធ្វើម៉េច ឆ្លើយតាមហ្នឹង តាមដំណើរដែលយើងបានធ្វើទៅណា យើងបានសម្លាប់ បានសម្លាប់មែន ប៉ុន្តែអាហ្នឹងច្បាប់អាំ ដាក់ទោសប៉ុន្មានឆ្នាំ ១០ឆ្នាំ ខ្ញុំជួយសម្រាលគាត់ ។

ភារិទ្ធៈ អូ!

ឌុចៈ ព្រោះគាត់សម្លាប់ដោយសារគេប្រើគាត់ដែរ អាហ្នឹងវាអញ្ចឹង គាត់មិនមែនមានចេតនាទេ ព្រោះខ្ញុំមើលនឹងភ្នែកថា មនុស្សទាំងអស់គ្មានអាណាចង់ធ្វើអញ្ចឹងទេអូន អត់ទេ ប៉ុន្តែបើឡានមួយ គេបើកទំលាក់ជ្រោះយើងទៅ ហក់ចេញឯណា យើងមិនរាប់ អញ្ចឹងគេបិទទ្វារជិតទៅ វានៅតែជិតដដែលហ្នឹង ។

ភារិទ្ធៈ ហើយចុះពូដែលលឺពាក្យថាពារ៍រំងាប់ដោយសារការមិនចងពៀរទេ?

ឌុចៈ ខ្ញុំលឺអូន ខ្ញុំចេះតែនឹកឃើញអញ្ចឹង ខ្ញុំនឹកឃើញថា យើងកើតមកជាមនុស្ស យើងមិនត្រូវយកពៀរយកទៅសងដោយពៀរវិញទេ បើមានពៀរយើងត្រូវរំងាប់ដោយពៀរ ។

ភារិទ្ធៈ មានន័យថាយ៉ាងម៉េច?

ឌុចៈ មានន័យថា បើគេសម្លាប់យើងយើងមិនត្រូវសម្លាប់គេទេ បើគេដេរយើង យើងត្រូវដើរចេញ យើងដេកលក់ យើងមិនត្រូវតបត អាហ្នឹងគេថា កំហឹងទល់កំហល់ ។

ភារិទ្ធៈ អូ បាទ ។

ឌុចៈ អំពើហិង្សាដែលកើតឡើង គឺវាមិនមែនកើតឡើង តែមនុស្សម្នាក់ហ្នឹងកើតទេ ខ្ញុំមិនដែល អូនឯងមកជេរខ្ញុំកើតទេ ឃើញទេ សុខៗអូនឯងមកជេរខ្ញុំកើត អាគាត់ឯងស្អីអញ្ចេះ អញ្ចុះមិនដែលមកនិយាយកើតទេ ដល់តែខ្ញុំហ្នឹងដើរទៅជួនកាលវាទើសជើងអូនឯងបន្តិច អូនឯងចិត្តទោសៈ មោហៈ មានចិត្តខឹង ត្រឡេបត្រឡប់ ក្រេវក្រោធមក ខ្ញុំអាក្រេវក្រោធហ្នឹង បើខ្ញុំយកពៀរ យកអំពើក្រេវក្រោធហ្នឹងទៅតបអូនឯងវិញ អត់កើតទេ ព្រោះខ្ញុំត្រូវគិត ខ្ញុំថា ខ្ញុំទើសគាត់មែន ប៉ុន្តែឥលូវបើគាត់ខឹងហើយ ខ្ញុំត្រូវអត់ទៅ ខ្ញុំដើរចេញទៅ អញ្ចឹងបានខ្ញុំរស់នៅបានសុខ ដោយសារខ្ញុំមិនចេះចងពៀរ ហើយខ្ញុំមិនចេះប្រព្រឹត្តអ្វី ដែលថាខុសពីឧត្តមគតិខ្លួនឯងធ្វើ ខ្ញុំធ្វើតាមកំលាំង តាមអត្មា ជីវខ្ញុំរកតាមកំលាំង តាមគំរិះ តាមប្រាជ្ញាអញ្ចឹងទៅ ប៉ុន្តែខ្ញុំគ្រាន់តែមើលឃើញទៅ យើងទៅរស់នៅក្នុងសង្គមដូចគេ ហើយអ្នកដែលថាយើង បានដឹងថាយើង អ្នកមធ្យម នៅមានអ្នកទាបជាងយើងទៅទៀត ដែលគ្នាស្រែកឃ្លាន ទាបជាងយើងទៅទៀត អញ្ចឹងបានថា បើថាសង្គមហ្នឹងយុត្តិធម៌ មនុស្សគ្មាន សព្វថ្ងៃមនុស្ស សព្វថ្ងៃមនុស្សដណ្តើមគ្នារស់ មិនខុសពីបាចបាយដណ្តើមគ្នាស៊ីទេ ដណ្តើមគ្នារស់ អញ្ចឹងរាល់ថ្ងៃ។

ភារិទ្ធៈ ហើយចុះពូ អ្នកដែលស្លាប់ជំនាន់ខ្មែរក្រហម ដែលត្រូវគេសម្លាប់ គេអីហ្នឹងតើពូយល់ថាជាកម្មជាពៀរ របស់អ្នកហ្នឹង?

ឌុចៈ មិនមែនទេ បើនិយាយពីកម្មពៀរ កម្មផលតាមធម៌ព្រះ ធម៌ព្រះពុទ្ធ ប៉ុន្តែបើសិនជានិយាយពីអាណាចក្រវិញមិនត្រូវទេ អានេះច្បាប់គេដាក់មកអញ្ចឹង ច្បាប់គឺបុគ្គលប៉ុន្មាននាក់អ្នកបង្កើត មិនមែនជាកម្មផលទេ។ កម្មផលវាមានមែន ប៉ុន្តែដល់តែអ្នកហ្នឹងប្រព្រឹត្តអំពើណាដែលប៉ះពាល់ហើយចុះគ្នា គ្រាន់តែហេវបាយសម្លាប់ដែរ អូនឯងប៉ះពាល់អីដែរ បើគ្រាន់តែគ្នាថាឃ្លានសម្លាប់ដែរ អញ្ចឹងរឿងហ្នឹងមិនមែនរឿងកម្មផលទេ គឺរឿងចេតនាទាំងមូលតែម្តង រឿងចេតនាតែម្តង មិនមែនកើតឡើងដោយអចេតនាទេ ខ្ញុំលឺសូរ លោកខៀវ សំផន និយាយនៅក្នុងវិទ្យុដែរ គាត់និយាយថាគាត់ អត់ដឹងទេ គាត់ស្មានតែល្អ ប៉ុន្តែខ្ញុំជឿថា អ្នកមេដឹកនាំមួយទាំងមូលមិនដឹងទេ។

ភារិទ្ធៈ អូ!

ឌុចៈ ឆ្ងល់ទេ បើខ្ញុំឆ្ងល់ បើគ្រាន់តែលឺគេថាទេ បើសិនជាអញ្ចឹងដដែល មិនដូចរាល់ថ្ងៃ ដូចរាល់ថ្ងៃក៏អញ្ចឹងដែរ ខ្ញុំនិយាយអោយចំតែម្តងរាល់ថ្ងៃ ក៏អញ្ចឹងដែរ សួរថាប្រជាជនរាល់ថ្ងៃ សម្តេចហ៊ុន សែន លោកស្រែកថា មិនអោយប្រជាជនណាមួយដាច់ពោះស្លាប់ដោយសារអត់បាយទេ ប៉ុន្តែបើសិនជាយកអង្ករមកចែកអ្នកអត់ គឺបានតែត្រឹមមេឃុំមេភូមិ ហើយសុទ្ធតែមានម៉ូតូហើយឡានទៅដឹកយកទៅលក់ពេញផ្សារ ហើយអ្នកអត់នៅតែអត់ដដែល អញ្ចឹងបានខ្ញុំថាវាដដែល ជាដដែលហ្នឹង ជំនាន់នោះហើយនេះ វាមិនខុសគ្នាប៉ុន្មានទេ គ្រាន់តែវាប្រែពណ៌ ។

ភារិទ្ធៈ ហើយចុះពូ ខ្ញុំចង់សួរទៀត ពូយល់យ៉ាងម៉េចចំពោះរបបបីឆ្នាំ ៨ខែ ២០ថ្ងៃ ដែលដឹកនាំអោយបំបាត់សាសនាចោល បំបាត់ចោលអីអញ្ចឹងអាំ ពូយល់ថាការធ្វើអញ្ចឹង វាអាចទៅរួចទេ?

ឌុចៈ វា បើសិនជាគិតទៅ អូនបញ្ហានេះ ខ្ញុំវាអត់សូវចេះអារឿងបញ្ហានយោបាយហ្នឹងជ្រៅជ្រះទេ ប៉ុន្តែគ្រាន់តែខ្ញុំតាមយល់នៅក្នុងចិត្ត ។

ភារិទ្ធៈ បាទ ។

ឌុចៈ ឧត្តមគតិរបស់ខ្ញុំទេណា ខ្ញុំចង់ឧទាហរណ៍ប្រាប់អូនមួយមាត់អញ្ចេះទៅណា ឧទាហរណ៍ថាឫស្សីមួយគុម្ពអញ្ចឹង អូនឯងឃើញអាក្នុងត្រង់ល្អហើយណា អូនឯងចង់កាប់យកអាក្នុងហើយអូនឯងចូលទៅកាត់ អូនឯងធ្វើយ៉ាងម៉េច អូនឯងមិនធ្វើយ៉ាងម៉េច មិនត្រូវឆ្ការក្រៅចូលទៅ ព្រោះឫស្សីវាមានមែកវាហើយណា ត្រូវឆ្ការ ។

ភារិទ្ធៈ បាទ!

ឌុចៈ វាឆ្ការទៅវាកាប់ហើយ វាប៉ះពាល់ហើយ អាដើមក្រៅ អាតូចតាចអីអាណា វាត្រូវកាប់ចោលហើយ វាទើស ។

ភារិទ្ធៈ បាទ ។

ឌុចៈ បានយើងចូលទៅដល់ក្នុង ។

ភារិទ្ធៈ អឺ!

ឌុចៈ មុននឹងឈានចូលទៅ ដល់អីមួយ គេត្រូវមួយមាត់អញ្ចឹងថា ឥលូវដូចថាខ្ញុំអ្នកចេះចង់ដឹកនាំម្នាក់ឯង ហើយនោះ ក៏ចេះ នេះក៏ចេះ នោះក៏ចេះដែរ អញ្ចឹងធ្វើម៉េចបើថា ខ្ញុំថា

“ត” ប្អូនឯងថា“ខ” ខ្ញុំថា“ក” អូនឯងថា“គ” ហើយអញ្ចឹងអ្នកចេះច្រើន អញ្ចឹងដើម្បីឲ្យខ្ញុំមានមោទនៈ គឺខ្ញុំដឹកនាំម្នាក់ឯងអោយបានល្អ អូនឯងអត់ទុកទេ ខ្ញុំសម្លាប់អូនឯងចោល ព្រោះខ្ញុំមានអំណាចដាច់ សម្លាប់ចោល អូនឯងលែងដឹង ខ្ញុំថា លិចគឺលិច កើតគឺកើតទៅ ប្រឆាំងជាមួយខ្ញុំអាហ្នឹងអញ្ចឹង ខ្ញុំយល់អញ្ចឹងនៅក្នុងចិត្តខ្ញុំ ខ្ញុំយល់ថាអញ្ចឹង ព្រោះវាសម្លាប់អូនឯងមើល តែបញ្ញវ័ន្ត, គ្រូបង្រៀន, និស្សិត, ទាហាន, ប៉ូលីសដែលមានបណ្តាសក្តិធំៗ គឺសម្លាប់ទាំងអស់ ហើយបើថា ឧទាហរណ៍អញ្ចេះមួយទៀតអោះ សូម្បីតែមេភូមិវា មេឃុំវា ជំនាន់នោះ មិនដែលយកអ្នកចេះអក្សរទៅធ្វើទេអូន អត់យកធ្វើទេ យកតែអ្នកអត់ចេះសុទ្ធ អត់ចេះអក្សរមួយតួ ពីដើមហ្នឹង មនុស្សពីដើមដែលគេហៅមនុស្ស គាត់មិនសូវចេះអក្សរ គាត់មិនដែលបានរៀន ព្រោះគាត់អ្នកក្រីក្រ វណ្ណៈក្រីក្រជំនាន់ហ្នឹង គេមិនថាអញ្ចឹង ហើយគ្នាពីដើមអ្នកក្រ អ្នកអត់អី គេមិនសូវបានទៅរៀនអីខ្ពង់ខ្ពស់ទេ ម្ល៉ោះហើយវាអត់ចេះទៅ ដល់តែអត់ចេះទៅ យកអ្នកក្រហ្នឹង យកទៅធ្វើ។

ភារិទ្ធៈ មេដឹកនាំខ្មែរក្រហមគួរតែអត់អោនទោសដែរឬអត់?

ឌុបៈ ខ្ញុំនិយាយទៅ មិនគួរអត់អោនទេអូន គួរអញ្ចេះ គួរថា ឲ្យអង្គការសហប្រជាជាតិហ្នឹងកាត់ទោសតាមច្បាប់ទៅ ហើយបើថាយើងចង់សម្រាលទោស កាត់ទោសហើយ វាខ្មែរដែរ កាលហ្នឹងវាខុសទៅហើយ ធ្វើទៅយ៉ាងម៉េច ហើយមកធ្វើតាមដំណើរអញ្ចឹងក៏បាន អាហ្នឹងតាមចិត្តខ្ញុំយល់ទេណា តែមិនដឹងជាត្រូវខុសទេអូន បើថាយើងខ្មែរដែរ ប៉ុន្តែមិនគួរថាទុកខ្មែរ ខ្មែរដែលខួរក្បាលសុទ្ធ។

ភារិទ្ធៈ ហើយចុះពូ ដូចថា ខ្មែរសម្លាប់ខ្មែរអញ្ចឹង ពូជឿថាមានអាអ្នកបញ្ជារពីក្រោយ ការឆ្លងកាត់?

ឌុបៈ រឿងនេះ បើសិនខ្ញុំថា ដូចសម្ងាត់ពិសអូន បើតាមខ្ញុំមើលទៅ វាប្រតេប្រតាយមករហូត ប៉ុន្តែយើងមិនអាចប្រៀបធៀបទៅពីនេះ ទៅភ្នំពេញកើតទេ ខ្ញុំគ្រាន់តែធៀបផ្ទះខ្ញុំត្រឹមថ្នល់ខាងកើតទេ។ ជំហានខ្ទីបំផុត ព្រោះពីភូមិ ភូមិមានទំនាក់ទំនងមកឃុំ។ ឃុំទំនាក់ទំនងទៅស្រុក ស្រុកទៅខេត្ត ខេត្តទៅភូមិភាគ ភូមិភាគទៅលើ ទៅលើៗទៀតមិន ដឹងទៅណា អាហ្នឹងមិនមែនថាម្នាក់ឯងហ្នឹងអាចធ្វើកើតទេ ព្រោះគេធ្វើហ្នឹងមិនដែលគេ គិតថាត្រូវឬខុស ចំណេញឬខាត គេវិភាគខ្លួនគេទៅ យើងមិនអាចសន្និដ្ឋានត្រូវអាហ្នឹង ខ្ញុំអត់ហ៊ាន

យល់ទេ ខ្ញុំយល់មិនដល់ទេ គ្រាន់តែយល់ថាអំពើដែលធ្វើ៣ឆ្នាំ ៨ខែ មិនគួរណា នឹងកើតឡើងនៅលើប្រទេសយើងទេ ។

ភារិទ្ធៈ ហើយចុះរឿងស្អី ដែលពូឈឺចាប់ជាងគេនៅក្នុងជំនាន់ហ្នឹង?

ឌុចៈ ខ្ញុំជំនាន់នោះដែលខ្ញុំឈឺចាប់បំផុត ឈឺចាប់ទីមួយ ព្រាត់ប្រាសឪពុកម្តាយម៉ែឪហ្នឹង តែម្តង ទីពីរគឺអត់បាយ ស្លាប់អត់បាយហើយ ទីបីហើយបើថាមានទោសហើយ គឺត្រូវកាត់ទោស បើត្រូវមានច្បាប់ ហើយបើគ្រាន់តែគ្នាហេវបាយក៏យកទៅសម្លាប់ដែរ ដូចជាវាអត់ច្បាប់ពេក ។

ភារិទ្ធៈ បាទ !

ឌុចៈ អាហ្នឹងគួរណាស់ដែរ ឈឺចាប់តែប៉ុណ្ណឹងទេ ខ្ញុំបើសិនជាគេថា ឥលូវគេធ្វើអញ្ចឹង ក៏ធ្វើចុះ ប៉ុន្តែអោយមានច្បាប់មានទំលាប់ត្រឹមត្រូវ អាណាធ្វើ ថាធ្វើ អាឃ្លានថា ឃ្លានទៅអោយត្រង់ៗទៅ ។

ភារិទ្ធៈ ហើយចុះពេលដែលពូនឹកឃើញរបបខ្មែរក្រហម ពូនឹកឃើញ ពូខឹងអញ្ចឹង ពូធ្លាប់ដោះស្រាយ យ៉ាងម៉េចដើម្បីអោយអារម្មណ៍រាងធូរវិញ?

ឌុចៈ ខ្ញុំប្រាប់អូនឯងត្រង់ បើខ្ញុំនឹកឃើញអាហ្នឹង ខ្ញុំអត់និយាយ ខ្ញុំអត់និយាយរកកូន រកចៅអីទេ ខ្ញុំនឹកឃើញអញ្ចឹង បើកាលណាខ្ញុំនិយាយ ហើយគ្នាអត់ដឹងអីសោះ ហើយគ្នាកំពុងតែខំរៀន ។

ភារិទ្ធៈ អូ!

ឌុចៈ ទៅជាលឺពីការឈឺចាប់របស់ឪពុកម្តាយទៅវានឹកឃើញ ក្រែងល់អញទៅមុខទៅចាស់ដែរទៅ អញ្ចឹងវាប៉ះពាល់ដល់អារម្មណ៍របស់វា កុំអោយនិយាយ ។

ភារិទ្ធៈ ដែលធ្លាប់និយាយរឿងរ៉ាវឈឺចាប់ហ្នឹង ប្រាប់កូនពូ?

ឌុចៈ ខ្ញុំអត់ដែលនិយាយទេ គ្រាន់តែថាកូនអើយ កូនឯងរស់នៅសព្វថ្ងៃនេះ វាសំណាងហើយកូនជំនាន់ប៉ុល ពត កូនអើយ បបរមួយវែក ក៏ឆ្អែតដែរកូន មិនមែនមួយវែកហើយថាមិនឆ្អែតទេណា ។

ភារិទ្ធៈ ហើយចុះពូធ្លាប់ ធ្លាប់គិតថាធ្វើម៉េចដើម្បីកុំអោយរបបហ្នឹង វិលមកវិញ?

ឌុចៈ ខ្ញុំថា លុះត្រាតែកាត់ទោសខ្មែរក្រហមហ្នឹង កុំអោយមាននៅតែម្ដង បើថាមាននៅ មិនខុស ដូចពីដីឡូងក្រវ៉ាញជ្រូក បោះចុះ បោះឡើងនៅតែមានដុះអញ្ចឹង ទោះជាយើងកាប់ ៨-១០ដងនៅតែមានដុះអញ្ចឹងអូន អញ្ចឹងត្រូវតែប្រមូលកាត់ទោសហ្នឹងតែម្ដង បានខ្ញុំថា

ភារិទ្ធៈ ហើយចុះពូជិនាន់ខ្មែរក្រហមពូមានធ្លាប់លឺពាក្យ ជីកស្មោ ជីកទាំងឫសទេ?

ឌុចៈ លឺ អីមិនលឺ ជីកស្មោជីកទាំងឫស ។

ភារិទ្ធៈ អាហ្នឹងវា?

ឌុចៈ អាហ្នឹង គេនិយាយគេមានគោលបំណងគេអញ្ចេះ ឧទាហរណ៍ថា សម្លាប់អូនឯងមួយ អូនឯងមានប្រពន្ធ អូនឯងមានកូន មិនអញ្ចឹងទេ សម្លាប់អូនឯងសម្លាប់កូន ទុកកូន សងសឹកអញ្ចឹង សម្លាប់កូនទៀត សម្លាប់ប្រពន្ធទៀត សម្លាប់ម៉ែឪទៀតអញ្ចឹង អារឿងបញ្ហាសងសឹកមានអ្នកណាសងសឹកទៀត និយាយពីរឿងគេអត់ដឹង ។

ភារិទ្ធៈ អញ្ចឹងត្រូវដែរ?

ឌុចៈ ខ្ញុំថាអត់ត្រូវទេអូន អ្នកដែលគ្នាអត់ទោសនេះដែលស្លាប់ដែរនេះ ឧទាហរណ៍ថាខ្ញុំធ្វើខុសប្រពន្ធខ្ញុំអត់ដឹងអីផងហ្នឹង ហើយដល់តែខ្ញុំជាប់គុកទៅ ទៅយកប្រពន្ធដាក់គុកដែរ ដូចអត់ទំនង គ្នាអត់ដឹងផង អញ្ចឹងវាអត់ច្បាប់តែម្ដងអូន និយាយរួមវាអត់ចាប់តែម្ដង ច្បាប់វាមាន ប៉ុន្តែច្បាប់វាទៅអញ្ចឹងតែម្ដង ជំនាន់ប៉ុល ពត វាមានរដ្ឋធម្មនុញ្ញវា ប៉ុន្តែរដ្ឋធម្មនុញ្ញវាទៅអញ្ចឹងតែម្ដង វាអោយសម្លាប់មនុស្សអញ្ចឹងតែម្ដង វាមិនមែន ។

ភារិទ្ធៈ ពូយល់ថាអារឿងរ៉ាវឈឺចាប់ហ្នឹង គួរតែអោយក្មេងនៅតាមសាលារៀនសូត្រ អោយបានដឹងលឺ?

ឌុចៈ ខ្ញុំថា រឿងនេះ ក្មេងៗវាមានច្រើន ក្មេងខ្លះដឹងទៅខូច ខ្ញុំនិយាយអញ្ចឹងតែម្ដង ក្មេងខ្លះខូចសុទ្ធតែសងសឹក មានបងតូច មានបងធំ សុទ្ធតែអញ្ចឹងតើ ជំនាន់ប៉ុល ពត ពេលកាលទៅវាមានអញ្ចឹងទៅ ឥលូវវាអប់រំ វាពិបាកអូន អារឿងក្មេងសម័យនេះ ។

ភារិទ្ធៈ អាហ្នឹង យើងនិយាយដឹង ហើយចុះបើមនុស្សខ្លះការយល់ដឹង វាយ៉ាងម៉េចវិញ?

ឌុចៈ យល់ដឹងពីសង្គមវាល្អ ប៉ុន្តែរឿងណា ដែលត្រូវមិនអាចអោយវាដឹង អត់អោយដឹងតែម្ដងវាល្អជាង ។

ភារិទ្ធៈ អារឿងខ្មែរក្រហមគួរតែ?

ឌុចៈ អារឿងខ្មែរក្រហមគួរអោយដឹង មើលនៅក្នុងសៀវភៅ វាអំពើឧក្រិដ្ឋកម្មវាអញ្ចេះៗគួរឲ្យអោយដឹង ប៉ុន្តែអំពើទារុណកម្ម កាប់សម្លាប់អីហ្នឹង អាហ្នឹងគេថា មិនត្រូវអោយស៊ីជំរៅពេកទេ ខ្លាចក្មេង អាក្រោយហ្នឹង វាយកតំរាប់តាមទៀត នឹកឃើញអញ្ចឹងទៀត ។

ភារិទ្ធៈ ពូថា មិនហ៊ាននិយាយ មិនហ៊ាននិយាយពីរឿងអី ប្រាប់កូន?

ឌុចៈ មិនហ៊ាននិយាយរឿងឈឺចាប់ ការឈឺចាប់ហ្នឹងអូននិយាយទៅ នាំតែថា ឪអញលំបាកវេទនាអីអញ្ចេះអញ្ចុះ ម៉្លោះហើយអារម្មណ៍ ចេះតែមានហើយអញ្ចឹងអាការ ដែលនិយាយទៅវាប៉ះទង្គិច លើផ្លូវចិត្ត ខ្ញុំមិនអាចមើលកូនធុះថា កូនហ្នឹងវាមានគំនិតវាទៅខាងណាខាងណា វាអត់ដឹង កូន៣-៤នាក់ មិនដឹងជាគំនិតវាទៅស្អី បើនិយាយទៅវានេះអញ្ចេះអញ្ចុះ ហើយបើថាវានិយាយថាមិនជឿមួយម៉ាត់ អាហ្នឹងយើងមិនគួរណាស់និយាយហើយ បើថាមិនជឿមិនគួរណាស់នឹងនិយាយ ។

ភារិទ្ធៈ ធ្វើម៉េចអោយក្មេងជឿ?

ឌុចៈ ទាល់តែផ្សព្វផ្សាយអប់រំវាទៅមុខទៀត អោយវាយល់ដឹង និយាយទៅវាអត់ជឿ ខ្ញុំនិយាយទៅ វាអត់ជឿអញ្ចឹង អារឿងដែលថាអត់ជឿហ្នឹង បានខ្ញុំថា មិនគួរណាស់តែនឹងនិយាយ ខ្ជិល ។

ភារិទ្ធៈ អូ!

ឌុចៈ បាទ ព្រោះថាអត់ជឿទៅហើយ វាមិនដែលអាណាគេយកមនុស្សទៅសម្លាប់ វាផុយអញ្ចឹង អត់ជឿទេ កូនមិនដែលឃើញ មិនដែលឈឺចាប់ អត់ដឹងខ្ញុំនិយាយ ជួនកាលរឿងខ្លះ មិនអញ្ចឹង ។

ភារិទ្ធៈ អញ្ចឹងខ្ញុំចង់សួរមួយសំនួរទៀត ដូចថាមនុស្សយើង បើសិនជា មានបញ្ហាផ្លូវចិត្ត ឈឺចាប់ដោយសារតែរឿងរ៉ាវដែលកើតចេញពីរបបខ្មែរក្រហម តើតាមរយៈសាសនាៗ តើអាចជួយអោយអ្នកហ្នឹងធូរទេ?

ឌុចៈ បាទ ខ្ញុំថាអាហ្នឹង អាចប្តូរអារម្មណ៍មនុស្សកើត ។

ភារិទ្ធៈ ជួយយ៉ាងម៉េច?

ឌុចៈ ព្រោះមនុស្សកាលណា ចាប់ពីវ័យ៥០ឡើង គឺមនុស្សចូលនិវត្តន៍សម័យចាស់ៗ គឺអញ្ចឹងតែម្តងគាត់ថា តែគាត់៥០ជាង គាត់ចូលវត្តចូលវ៉ាហើយ នែអញ្ចឹងអា៎ អាហ្នឹងខ្មែរ

យើងចាស់ៗ គាត់ច្រើនតែនិយាយអញ្ចឹង ហើយអាខ្លះតាំងថាអញ មិនទាន់ចូល៥០ទេ អញមិនទាន់ចូលវត្តទេ ច្រើនតែអញ្ចឹង ហើយអាការផ្សព្វផ្សាយ គាត់ចូល៥០ហ្នឹង អាហ្នឹងបានគាត់ដឹង បើក្មេងក្រោយ បើដឹង ក៏ដឹងតិចដែរ ដូច ខ្ញុំ ដឹង ដឹងតិចអាំ បើគាត់ គាត់អាយុ ២០ឆ្នាំកាលពីជំនាន់ ប៉ុល ពត គឺគាត់អាចដឹងច្រើន២០ទៅ៣០ឆ្នាំ គាត់ឡើង ៦០ជាងហើយ៧០ ហើយអញ្ចឹង គាត់ចូលវត្តហើយ អញ្ចឹងគាត់អាចប្រមូលអារម្មណ៍ គាត់បានហើយ ព្រោះគាត់ចាស់ហើយ ។

ភារិទ្ធ: បាទ!

ឌុប: ហើយអើតាម ។

ភារិទ្ធ: ចង់និយាយអី?

ឌុប: អត់ទេ អញ្ចើញ ។

ភារិទ្ធ: ហើយពូ តាមគំនិតពូផ្ទាល់ ខ្ញុំចង់សួរចុងក្រោយ ពូយល់ថាធ្វើម៉េចដើម្បីអោយប្រទេស យើងសុខជា មានសន្តិភាព មានដូចថា មានយុត្តិធម៌ទៅថ្ងៃមុខ?

ឌុប: ខ្ញុំយល់ឃើញអូន នៅក្នុងពិភពលោកគេកាន់លទ្ធិប្រជាធិបតេយ្យគ្រប់គ្នា ប្រទេសដែល ជឿនលឿន គេកាន់លទ្ធិប្រជាធិបតេយ្យ សព្វថ្ងៃនេះយើងមិនមែនអ្នកដើរតួប្រជាធិប តេយ្យទេ យើងគ្រាន់តែមើលគេ ធ្វើតាមគេទៅបានហើយ ហើយយើងរស់នៅ មានច្បាប់មួយ ថាច្បាប់ ជាច្បាប់របស់ជាតិ គឺរដ្ឋធម្មនុញ្ញសុក្រិតតែម្តង អោយ ប្រជារាស្ត្រយើងទាំងអស់នៅក្រោមដំបូលច្បាប់ អោយគោរពច្បាប់ទាំងអស់ អាហ្នឹង ប្រហែលជាប្រជាជន ខ្មែរយើងសប្បាយចិត្តហើយជីវភាពក៏ធូរធារ តាមមើល ហើយ បើសិនជា លទ្ធិខុសពីប្រជាធិបតេយ្យហ្នឹង ដែលយើងធ្លាប់ឆ្លងកាត់មក ឃើញច្រើន អើយ វាមិនសូវដែលបាន ខ្មែរយើងដែលបានសុខសោះ ហើយ បានជាមានគំនៀល តាំងពីដើមមក ចាស់ៗៗយើងថា អើ ឯងកុំចេះដឹងអីពេក បៀមគ្រួស បៀមថ្មទៅ នែ អញ្ចឹងណា អញ្ចឹងអាការនិយាយស្តី ក៏អត់ហ៊ាននិយាយដែរទោះយើងដឹង ១០ គ បើ យើង ទៅប្ដូរគេ ១០ គ ក៏យើងមិនហ៊ាននិយាយដែរអាហ្នឹង ហើយចុះអាហ្នឹង យើង សម្លាប់គេ អញ្ចឹងយើង បៀមគ្រួសបៀមថ្មទៅ អញ្ចឹងអាំ អញ្ចឹងឃើញអ្នកខុសហើយ

ក៏មិនហ៊ាននិយាយដែរ ព្រោះ ខ្លាចអាហ្នឹងគេមកធ្វើបាបយើង គេមានលុយជាង គេដើរប្លន់រាល់ថ្ងៃ បានលុយច្រើន

ភារិទ្ធ: បាទ!

ចប់